ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍ប្រចាំឆ្នាំ ២០២១
# អំពីទីផ្សារធានារ៉ាប់រងកម្ពុជា





## ការធានារ៉ាប់រង






រៀបចំដោយ

និយ័តករធានារ៉ាប់រងកម្ពុជា

# មាតិកា


ផ្នែកទី១: សាររបស់ថ្នាក់ដឹកនាំ ........ 1

១.១. សាររបស់ប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ........ 2

១.២. សាររបស់អគ្គនាយកនៃនិយ័តករធានារ៉ាប់រងកម្ពុជា ........ 4

ផ្នែកទី២: និយ័តករធានារ៉ាប់រងកម្ពុជា ........ 5

២.១. រចនាសម្ព័ន្ធស្ថាប័ន ........ 6

២.២. និយ័តករធានារ៉ាប់រងកម្ពុជា ........ 9

២.២.១. តួនាទី និងភារកិច្ច ........ 9

២.២.២. និមិត្តសញ្ញា ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃរួម ........ 10

២.២.៣. សមាសភាពថ្នាក់ដឹកនាំនៃនិយ័តករធានារ៉ាប់រងកម្ពុជា ........ 13

ផ្នែកទី៣: ក្របខណ្ឌទីផ្សារធានារ៉ាប់រង ........ 14

៣.១. គ្រឹះស្ថានធានារ៉ាប់រង ........ 15

៣.១.១. ក្រុមហ៊ុនធានារ៉ាប់រង ........ 15

៣.១.២. អន្តរការីធានារ៉ាប់រង ........ 17

៣.២. ទីផ្សារធានារ៉ាប់រង ........ 18

៣.២.១. បុព្វលាភធានារ៉ាប់រង ........ 18

៣.២.២. បុព្វលាភធានារ៉ាប់រងតាមប្រភេទផលិតផលធានារ៉ាប់រង ........ 22

៣.២.៣. សំណងធានារ៉ាប់រងដែលបានកើតឡើង ........ 26

៣.២.៤. លទ្ធផលប្រចាំឆ្នាំ....................27

៣.២.៥. ទ្រព្យសកម្មនៃទីផ្សារឆានារ៉ាប់រង....................30

៣.២.៦. ទ្រព្យអកម្មធានារ៉ាប់រង....................31

៣.២.៧. មូលធនផ្ទាល់របស់ទីផ្សារធានារ៉ាប់រង....................32

៣.៣. ការបណ្តុះបណ្តាលវិជ្ជាជីវៈធានារ៉ាប់រង....................34

៣.៤. ការធានារ៉ាប់រងជាភាតព្វកិច្ច....................37

៣.៥. ការលើកកម្ពស់ការយល់ដឹងសាធារណៈ....................40

ផ្នែកទី៤: កិច្ចសហប្រតិបត្តិការ....................43

៤.១. កិច្ចសហប្រតិបត្តិការក្នុងប្រទេស....................44

៤.២. កិច្ចសហប្រតិបត្តិការក្រៅប្រទេស....................46

ផ្នែកទី៥: ក្របខណ្ឌបញ្ញត្តិកម្ម....................50

ផ្នែកទី៦: ការងារសខ្ខមរបស់ ន.ធ.ក....................54

ផ្នែកទី៧: សន្និដ្ឋាន....................58

© 2022, រក្សាសិទ្ធិដោយ និយ័តករធានារ៉ាប់រងកម្ពុជា( www.irc.gov.kh)

អគារលេខ ១៦៨F (ជាន់ទី៦) ផ្លូវលេខ ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កម្ពុជា

សម្របសម្រួលដោយ នាយកដ្ឋានស្រាវជ្រាវ បណ្ដុះបណ្ដាល និងសហប្រតិបត្តិការ

# ផ្នែកទី១: សាររបស់ថ្នាក់ដឹកនាំ

## ១.១. សាររបស់ប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ



ឆ្នាំ២០២១ គឺជាចំណុចចាប់ផ្តើមដ៏មានសារៈសំខាន់មួយ នៃវិស័យសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងជាការបើកទំព័រថ្មីមួយទៀតផងដែរ សម្រាប់ការអភិវឌ្ឍវិស័យធានារ៉ាប់រងកម្ពុជា។ ទាំងនេះគឺជាសមិទ្ធផលថ្មីមួយប្រកបដោយផ្លែផ្កា ដែលកើតចេញពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឆ្នើមប្រកបដោយគតិបណ្ឌិត និងចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការធ្វើពិពិធកម្មសេដ្ឋកិច្ច តាមរយៈការជំរុញការអភិវឌ្ឍ និងបង្កើនភាពសម្បូរបែបនៃផលិតផល និងសេវាកម្មហិរញ្ញវត្ថុ ទាំងធនាគារ និងមិនមែនធនាគារ។ ទន្ទឹមនឹងការរីកចម្រើនដ៏ឆាប់រហ័សនេះ វិស័យហិរញ្ញវត្ថុមិនមែនធនាគារនៅបន្តជួបបញ្ហាប្រឈមមួយចំនួនទៀត ដែលទាមទារឱ្យមានការផ្តោតការយកចិត្តទុកដាក់ ពិនិត្យ កែសម្រួល និងពង្រឹងបន្ថែមផងដែរ ដើម្បីបន្សល់មចំណែកជាប្រភពថ្មីនិងរឹងមាំនៃកំណើនសេដ្ឋកិច្ចកម្ពុជា។

ក្នុងបរិការណ៍នៃការបន្តអូសបន្លាយវិបត្តិជំងឺកូវីដ-១៩ ការកសាងភាពធន់ ការធានាស្ថេរភាពនិងការពង្រឹងសមត្ថភាពនៃប្រព័ន្ធហិរញ្ញវត្ថុ គឺជាអាទិភាពដ៏ចម្បងមួយរបស់រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងឆ្នាំ ២០២១ និងឆ្នាំបន្តបន្ទាប់ តាមរយៈការបន្តធ្វើពិពិធកម្មលើផលិតផលហិរញ្ញវត្ថុ និងអភិវឌ្ឍន៍ហេដ្ឋា-រចនាសម្ព័ន្ធប្រព័ន្ធហិរញ្ញវត្ថុបន្ថែមទៀត ជាពិសេសបច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech) ដើម្បីសម្របខ្លួននិងឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងការប្រែប្រួលនៃលក្ខខណ្ឌសេដ្ឋកិច្ចនិងសង្គម និងវិបត្តិនាពេលអនាគតផងដែរ។ ទោះយ៉ាងណាក៏ដោយ វិបត្តិជំងឺកូវីដ-១៩ និងសក្តានុពលនៃបរិវត្តកម្មឌីជីថល ដែលជាបញ្ហាដាច់ដោយឡែកពីគ្នា ប៉ុន្តែបាននិងកំពុងក្លាយជាកាតាលីករបំពេញឱ្យគ្នាទៅវិញទៅមកក្នុងសម្ទុះបន្ថែមទៀតសម្រាប់កម្ពុជាចាប់យកបច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីជំរុញវិស័យសេវាហិរញ្ញវត្ថុមិនមែនធនាគារឱ្យមានដំណើររីកលូតលាស់ប្រកបដោយបរិយាប័ន្ន។ ការទទួលយក និងបរិវត្តកម្មឌីជីថលសម្រាប់វិស័យ

សេវាហិរញ្ញវត្ថុមិនមែនធនាគារនឹងនាំមកនូវកាលានុវត្តភាពនៃប្រភពកំណើនថ្មី ព្រមទាំងការបង្កើនផលិតភាពសេដ្ឋកិច្ច ការបង្កើតការងារ និងការរួមចំណែកកាត់បន្ថយភាពក្រីក្រនិងវិសមភាពសង្គម។

នៅក្នុងបរិបទនៃការរីកចម្រើនដ៏ឆាប់រហ័សរបស់បច្ចេកវិទ្យាឌីជីថលនេះ បច្ចេកវិទ្យាធានារ៉ាប់រង (InsurTech) ដែលជាផ្នែកមួយនៃប្រព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ កំពុងជះឥទ្ធិពលយ៉ាងខ្លាំងលើវិស័យធានារ៉ាប់រង ទាំងក្នុងក្របខណ្ឌតំបន់និងអន្តរជាតិ និងចាប់ផ្តើមមានឥទ្ធិពលមកកាន់ទីផ្សារកម្ពុជាជាបណ្តើរៗផងដែរ ក្នុងន័យពង្រឹងនូវភាពប្រកួតប្រជែង និងភាពច្នៃប្រឌិតថ្មីរបស់វិស័យឯកជន ក៏ដូចជាប្រសិទ្ធភាពនៃការបំពេញការងាររបស់និយ័តករធានារ៉ាប់រងកម្ពុជា ក្នុងការត្រួតពិនិត្យ តាមដាននិងវាយតម្លៃស្ថានភាពអាជីវកម្មនិងហិរញ្ញវត្ថុ សំដៅធានាបាននូវភាពរឹងមាំនៃវិស័យធានារ៉ាប់រងនៅកម្ពុជា។

ថ្ងៃព្រហស្បតិ៍ ៧កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

## ១.២. សាររបស់អគ្គនាយកនៃនិយ័តករធានារ៉ាប់រងកម្ពុជា



ទីផ្សារធានារ៉ាប់រងនៅកម្ពុជា គឺជាទីផ្សារមួយដែលកំពុងមានការវិវត្តឆ្ពោះទៅមុខយ៉ាងឆាប់រហ័ស និងគួរឱ្យកត់សម្គាល់ពីមួយឆ្នាំទៅមួយឆ្នាំ។ គិតត្រឹមឆ្នាំ២០២១ មានក្រុមហ៊ុនធានារ៉ាប់រងទូទៅចំនួន ១៨ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតចំនួន១៤ ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចចំនួន៦ និងក្រុមហ៊ុនធានារ៉ាប់រងបន្តចំនួន ១ ដែលកំពុងធ្វើអាជីវកម្មក្នុងទីផ្សារធានារ៉ាប់រងកម្ពុជា ដោយមានទ្រព្យសកម្មប្រមាណ៨៤៥លានដុល្លារអាមេរិក និងមូលនិធិភាគហ៊ុនិកប្រមាណ ៣៧៨ លានដុល្លារអាមេរិក។ ក្រោមកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ជាលទ្ធផល ទីផ្សារធានារ៉ាប់រងបានរួមចំណែកក្នុងសេដ្ឋកិច្ចក្នុងអត្រាប្រមាណ ១,១១% ជាមួយនឹងដង់ស៊ីតេធានារ៉ាប់រងប្រមាណ ១៨,៧៥ដុល្លារអាមេរិកក្នុងមនុស្សម្នាក់។ ក្នុងគោលដៅ គាំទ្រនិងជំរុញល្បឿនបន្ថែមទៀតដល់ដំណើរការអភិវឌ្ឍន៍ទីផ្សារនិងវិស័យធានារ៉ាប់រងកម្ពុជា និយ័តករធានារ៉ាប់រងកម្ពុជាបានដាក់ចេញនូវ **“ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជា ២០២១-២០៣០”** ដោយផ្សារភ្ជាប់ជាមួយនូវសកម្មភាពការងារគន្លឹះៗជាអាទិភាពដើម្បីអនុវត្ត ទាំងក្នុងក្របខណ្ឌស្ថាប័ន ក្របខណ្ឌបច្ចេកទេស ក្របខណ្ឌបញ្ញត្តិកម្ម ក្របខណ្ឌទីផ្សារធានារ៉ាប់រង និងក្របខណ្ឌកិច្ចសហប្រតិបត្តិការ។ បន្ថែមពីនេះ សមិទ្ធផលប្រចាំឆ្នាំ២០២១ ជាច្រើនទៀត ត្រូវបានសម្រេចដូចជា ការដាក់ឱ្យអនុវត្តនូវគោលការណ៍ណែនាំអំពីការរៀបចំវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រង ការរៀបចំកែសម្រួលបទប្បញ្ញត្តិ ការអប់រំផ្សព្វផ្សាយដល់សាធារណជន ការជំរុញនិងលើកទឹកចិត្តដល់ការបង្កើតផលិតផលធានារ៉ាប់រងថ្មីៗ ការពង្រឹងវិធីសាស្ត្រត្រួតពិនិត្យផ្អែកលើកម្រិតហានិភ័យ និងការពង្រឹងសមត្ថភាពមន្ត្រីនៃនិយ័តករធានារ៉ាប់រងកម្ពុជា។

ថ្ងៃព្រហស្បតិ៍ ៤កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០២២

**អគ្គនាយក**

**និយ័តករធានារ៉ាប់រងកម្ពុជា**

**ប៊ូ ចន្ទភិរុ**

# ផ្នែកទី២: និយ័តករធានារ៉ាប់រងកម្ពុជា

## ២.១. រចនាសម្ព័ន្ធស្ថាប័ន

យោងតាមច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលបានចូលជាធរមានតាមរយៈព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ និយ័តករធានារ៉ាប់រងកម្ពុជា គឺជាសេនាធិការក្រោមឱវាទនៃ **អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (សរសេរកាត់ថា អ.ស.ហ.)** ដែលត្រូវបានបង្កើតឡើង និងមានឯករាជ្យភាពក្នុងការបំពេញមុខងាររបស់ខ្លួន ដោយធ្វើសមាហរណកម្មយន្តការនៃការគ្រប់គ្រង ត្រួតពិនិត្យ លើវិស័យហិរញ្ញវត្ថុមិនមែនធនាគារ មានជាអាទិ៍ វិស័យធានារ៉ាប់រងនិងសោធនឯកជន វិស័យមូលបត្រ វិស័យសន្តិសុខសង្គម វិស័យបរធនបាលកិច្ច វិស័យគណនេយ្យនិងសវនកម្ម និងវិស័យអចលនវត្ថុ វិស័យបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន នៅក្នុងគោលបំណងពង្រឹងនិងធានាប្រសិទ្ធភាពនៃការគ្រប់គ្រង ការត្រួតពិនិត្យ និងអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមិនមែនធនាគារ រួមទាំងការលើកកម្ពស់ការអភិវឌ្ឍនិងប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុលើវិស័យហិរញ្ញវត្ថុមិនមែនធនាគារនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**<u>តារាងទី១</u>**÷ អង្គការលេខនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ



# សមាសភាពក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ




***រូបភាពទី១*** ៖ សមាសភាពក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាប្រធាន
- ឯកឧត្តម **រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអនុប្រធាន
- ឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាសមាជិក
- ឯកឧត្តម **ខិ តាឃី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសមាជិក
- លោកជំទាវ **នាង ច័ន្ទថាណា** ទេសាភិបាលរងនៃធនាគារជាតិកម្ពុជា ជាសមាជិក
- ឯកឧត្តម **គីមរ័ត្ន វិសិដ្ឋ** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក
- លោកជំទាវ **តឹកវ៉េត គំរេង** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ជាសមាជិក

- ឯកឧត្តម **ម៉ី វ៉ាន់** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.** ជាសមាជិក
- ឯកឧត្តម **ស៊ូ សុជាតិ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា ជាសមាជិក
- ឯកឧត្តមបណ្ឌិត **ចន ណារិទ្ធ** អគ្គនាយកនៃនិយ័តករសន្តិសុខសង្គម ជាសមាជិក
- ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច ជាសមាជិក
- ឯកឧត្តម **ប៊ូ ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យ និងសវនកម្ម ជាសមាជិក
- ឯកឧត្តម **ប៊ូ ច័ន្ទភីរូ** អគ្គនាយកនៃនិយ័តករធានារ៉ាប់រងកម្ពុជា ជាសមាជិក
- ឯកឧត្តម **ជូ វណ្ណៈ** អគ្គនាយកនៃនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ ជាសមាជិក
- លោកបណ្ឌិត **សំ យុទ្ធី** អ្នកជំនាញអព្យាក្រឹត ជាសមាជិក
- លោកបណ្ឌិត **សំ សុខុម** អ្នកជំនាញអព្យាក្រឹត ជាសមាជិក
- លោកជំទាវ **យាន សុលីណា** អ្នកជំនាញអព្យាក្រឹត ជាសមាជិក។

## ២.២. និយ័តករធានារ៉ាប់រងកម្ពុជា

**និយ័តករធានារ៉ាប់រងកម្ពុជា** (សរសេរកាត់ថា **ន.ធ.ក.**) ត្រូវបំពេញមុខងារជាសេនាធិការឱ្យ **អ.ស.ហ.** និងត្រូវអនុវត្តសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចមានចែងក្នុងច្បាប់ស្តីពីការធានារ៉ាប់រងដែលបានប្រកាសដាក់ឱ្យប្រើប្រាស់ដោយ ព្រះរាជក្រមលេខ នស/រកម/០៨១៤/០២១ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៤ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតក្នុងវិស័យធានារ៉ាប់រង។

### ២.២.១. តួនាទី និងភារកិច្ច

និយ័តករធានារ៉ាប់រងកម្ពុជាមានតួនាទីនិងភារកិច្ចសំខាន់ៗមួយចំនួនដូចខាងក្រោម÷

| | | |
|---|---|---|
| ០១ | **ក្រុមខណ្ឌគោលនយោបាយ** | រៀបចំ និងអនុវត្តនូវគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃវិស័យធានារ៉ាប់រង និងសោធនឯកជន |
| ០២ | **ក្រុមខណ្ឌបញ្ញត្តិកម្ម** | រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យធានារ៉ាប់រងនិងសោធនឯកជន |
| ០៣ | **ក្រុមខណ្ឌទីផ្សារ** | ត្រួតពិនិត្យ តាមដាន និងវាយតម្លៃស្ថានភាពអាជីវកម្មនិងហិរញ្ញវត្ថុដើម្បីធានាភាពរឹងមាំរបស់គ្រឹះស្ថានធានារ៉ាប់រងនិងសោធនឯកជន |
| ០៤ | **ក្រុមខណ្ឌកិច្ចសហប្រតិបត្តិការ** | លើកកម្ពស់ការអប់រំ បណ្តុះបណ្តាល និងផ្សព្វផ្សាយដល់សាធារណជន និងចូលរួមក្នុងកិច្ចសហប្រតិបត្តិការក្នុងតំបន់និងអន្តរជាតិ |
| ០៥ | **ផ្សេងៗ** | តាមការណែនាំរបស់ក្រុមប្រឹក្សា **អ.ស.ហ.** |

## ២.២.២. និមិត្តសញ្ញា ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃរួម

រូបភាពទី២÷ និមិត្តសញ្ញានៃ ន.ធ.ក.

| | |
|---|---|
| **រូបហង្សពណ៌មាស** | តំណាងឱ្យអាជ្ញាធរហិរញ្ញវត្ថុ ដែលជាអ្នកគ្រប់គ្រង ត្រួតពិនិត្យប្រតិបត្តិការធានារ៉ាប់រង និងសោធនឯកជន និងធានាឲ្យដំណើរការទីផ្សារធានារ៉ាប់រងនិងសោធនឯកជនប្រកបដោយតម្លាភាព ប្រសិទ្ធភាព មាន សណ្តាប់ធ្នាប់ និងយុត្តិធម៌។ |
| **រូបខែល និងអក្សរ ន.ធ.ក.** | តំណាងឱ្យការការពារលើការបាត់បង់ផ្នែកហិរញ្ញវត្ថុ នៅពេលដែលមានហានិភ័យកើតឡើង (ធានារ៉ាប់រង) និងតំណាងឱ្យនិយ័តករធានារ៉ាប់រងកម្ពុជា។ |
| **រូបហង្សពណ៌មាសឈរលើខែល** | បង្ហាញពីដំណើរការនៃទីផ្សារធានារ៉ាប់រង និងសោធនឯកជន ស្ថិតក្រោមការគ្រប់គ្រង និងត្រួតពិនិត្យរបស់និយ័តករធានារ៉ាប់រងកម្ពុជាប្រកបដោយតម្លាភាព ប្រសិទ្ធភាព មានសណ្តាប់ធ្នាប់ និងយុត្តិធម៌។ |
| **រូបស្លឹកឈើ** | លទ្ធផលជាផ្លែផ្កា នៃការចូលរួមចំណែករបស់វិស័យធានារ៉ាប់រង និងសោធនឯកជន ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ |

## ចក្ខុវិស័យ

“ធានាបាននូវភាពរឹងមាំ និងឧត្តមភាពប្រកួតប្រជែងប្រកបដោយចីរភាពរបស់គ្រឹះស្ថានធានារ៉ាប់រងទាំងអស់ ដើម្បីបម្រើផលប្រយោជន៍ដល់ពលរដ្ឋកម្ពុជាគ្រប់រូប និងជំរុញកំណើនសេដ្ឋកិច្ចជាតិ”

## បេសកកម្ម

“ប្តេជ្ញាអនុវត្តគោលការណ៍គ្រប់គ្រង និងត្រួតពិនិត្យតាមនិយាមអន្តរជាតិប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ និងមានវត្បនភាព”

ចក្ខុវិស័យ + បេសកកម្ម → និយ័តករធានារ៉ាប់រងកម្ពុជា

## គុណតម្លៃរបស់ ន.ធ.ក.

<u>***រូបភាពទី៣***</u>÷ គំនូសបំព្រួញនៃគុណតម្លៃរបស់ **ន.ធ.ក.**

**ការទទួលខុសត្រូវ** (Responsibility)

ត្រូវមានគណនេយ្យភាព ភាពលះបង់និងភាពដឹកនាំ ដែលជាកត្តាចាំបាច់លើសពីការផ្តល់សេវាសាធារណៈ។




**សុចរិតភាព** (Integrity)

ប្រកាន់ខ្ជាប់នូវភាពស្មោះត្រង់និងតម្លាភាពកម្រិតខ្ពស់បំផុតក្នុងការបំពេញមុខងារ និងតួនាទីរបស់ខ្លួន។

**ឆន្ទៈ** (Commitment)

សម្រេចឱ្យបានតាមស្តង់ដារអន្តរជាតិកម្រិតខ្ពស់បំផុត និងឧត្តមានុវត្តក្នុងការងារគ្រប់គ្រងនិងត្រួតពិនិត្យ ដើម្បីបម្រើអតិថិជន និងឧស្សាហកម្មធានារ៉ាប់រងកម្ពុជា។

## ២.២.៣. សមាសភាពថ្នាក់ដឹកនាំនៃនិយ័តករធានារ៉ាប់រងកម្ពុជា

<u>**រូបភាពទី៤**</u>÷ សមាសភាពថ្នាក់ដឹកនាំនៃ ន.ធ.ក.



ឯកឧត្តម **ប៊ូ ច័ន្ទតិរៀ**
អគ្គនាយកនៃ
និយ័តករធានារ៉ាប់រងកម្ពុជា



លោកស្រីបណ្ឌិត **ហោ សុទឡូនា**
អគ្គនាយករង



លោកស្រី **តាន់ លីណា**
អគ្គនាយករង



លោក **ង៉ា វិជ្ជា**
ប្រធាននាយកដ្ឋាន
នាយកដ្ឋានគ្រប់គ្រងអាជ្ញាបណ្ណ
និងកិច្ចការគតិយុត្ត



លោក **នូច ម៉េងឡេង**
ប្រធាននាយកដ្ឋាន
នាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារ



លោកស្រី **ង៉ាន់ លក្ខិណា**
ប្រធាននាយកដ្ឋាន
នាយកដ្ឋានកិច្ចការទូទៅ



លោក **ខុង អៀហៃ**
ប្រធាននាយកដ្ឋាន
នាយកដ្ឋានស្រាវជ្រាវ
បណ្តុះបណ្តាល និងសហប្រតិបត្តិការ



លោកស្រី **លុយ ម៉ីអ៊ី**
ប្រធាននាយកដ្ឋាន
នាយកដ្ឋានត្រួតពិនិត្យ

# ផ្នែកទី៣: ក្របខណ្ឌទីផ្សារធានារ៉ាប់រង

# ៣.១. គ្រឹះស្ថានធានារ៉ាប់រង

## ៣.១.១. ក្រុមហ៊ុនធានារ៉ាប់រង

ចាប់តាំងពីឆ្នាំ២០១៧ មកដល់បច្ចុប្បន្ន វិស័យធានារ៉ាប់រងកម្ពុជា មានការរីកចម្រើនយ៉ាងឆាប់រហ័ស ដែលចំនួនក្រុមហ៊ុនធានារ៉ាប់រងផ្ទាល់មានការកើនឡើងពីចំនួន ២៦ ក្នុងឆ្នាំ២០១៧ រហូតដល់ចំនួន៣៩ ក្នុងឆ្នាំ២០២១។ ទោះបីជាមានវិបត្តិកូវីដ-១៩ក៏ដោយ គិតត្រឹមចុងឆ្នាំ២០២១ **ន.ធ.ក.** បានផ្តល់អាជ្ញាបណ្ណអាជីវកម្មក្រុមហ៊ុនធានារ៉ាប់រងទូទៅចំនួន១៨ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតចំនួន ១៤ និងក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចចំនួន ៧។ ក្រុមហ៊ុនទាំងនេះ មានទាំងប្រភេទក្រុមហ៊ុនបរទេសចំនួន ២៣ ក្រុមហ៊ុនក្នុងស្រុកចំនួន១៥ និងក្រុមហ៊ុនចំរុះរដ្ឋចំនួន ១។

បច្ចុប្បន្ន ទីផ្សារធានារ៉ាប់រងកម្ពុជា មានតែក្រុមហ៊ុនធានារ៉ាប់រងបន្តមួយគត់ គឺក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជារី" ដែលវិវត្តខ្លួនពីក្រុមហ៊ុនរដ្ឋ មកជាក្រុមហ៊ុនចំរុះដែលមានភាគហ៊ុនរដ្ឋ ៨០% និងចុងក្រោយបានធ្វើឯកជនភាវូបនីយកម្មបន្ត ដោយមានភាគហ៊ុនរដ្ឋតែ ៦០.២១%។

**<u>រូបភាពទី៥</u>**÷ ចំនួនក្រុមហ៊ុនធានារ៉ាប់រង




*ប្រភព÷ និយ័តករធានារ៉ាប់រងកម្ពុជា*

**រូបភាពទី៦**÷ ប្រភេទក្រុមហ៊ុនធានារ៉ាប់រង




*ប្រភព÷ និយ័តករធានារ៉ាប់រងកម្ពុជា*

**រូបភាពទី៧**÷ប្រភពទុននៃក្រុមហ៊ុនធានារ៉ាប់រង




*ប្រភព÷ និយ័តករធានារ៉ាប់រងកម្ពុជា*

## ៣.១.២. អន្តរការីធានារ៉ាប់រង

ចំពោះអន្តរការីធានារ៉ាប់រងដែលរួមមានក្រុមហ៊ុនជើងសាធានារ៉ាប់រង និងក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង បានដើរតួយ៉ាងសំខាន់ក្នុងវិស័យធានារ៉ាប់រងកម្ពុជា ដើម្បីចែកចាយផលិតផលធានារ៉ាប់រងឱ្យបានកាន់តែទូលំទូលាយនិងនាំយកផលិតផលធានារ៉ាប់រងឱ្យកាន់តែខិតជិតអតិថិជន។ ដើម្បីគាំទ្រដល់ការរីកចម្រើននៃវិស័យធានារ៉ាប់រងសំដៅពង្រឹងនិងពង្រីកសំណាញ់សុវត្ថិភាពសង្គម ចំនួនក្រុមហ៊ុនអន្តរការីធានារ៉ាប់រង មានការកើនឡើងពីចំនួន ២៨ ក្នុងឆ្នាំ២០១៧ រហូតដល់ចំនួន៤៣ ក្នុងឆ្នាំ២០២១។ គិតត្រឹមចុងឆ្នាំ២០២១ ទីផ្សារធានារ៉ាប់រងមានក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រងចំនួន ២៦ និងក្រុមហ៊ុនជើងសាធានារ៉ាប់រង ១៧។

<u>រូបភាពទី៨</u>÷ ចំនួនអន្តរការីធានារ៉ាប់រង




*ប្រភព÷ និយ័តករធានារ៉ាប់រងកម្ពុជា*

## ៣.២. ទីផ្សារធានារ៉ាប់រង

ការរីករាលដាលនៃវិបត្តិជំងឺកូវីដ-១៩ បានដាក់សម្ពាធយ៉ាងធ្ងន់ធ្ងរដល់ប្រភពកំណើនសេដ្ឋកិច្ចកម្ពុជា ដោយក្នុងនោះឃើញថា កំណើនសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០២០ បានថយចុះដល់ -៣,១% និងងើបឡើងវិញដល់ ៣% ក្នុងឆ្នាំ២០២១ តាមរយៈការដាក់ចេញនូវវិធានការទប់ស្កាត់ទាន់ពេលវេលារបស់រាជរដ្ឋាភិបាលកម្ពុជា។ ទោះបីស្ថិតក្នុងបរិការណ៍នៃវិបត្តិជំងឺកូវីដ-១៩ ក៏ដោយ ក៏វិស័យធានារ៉ាប់រងកម្ពុជា នៅតែបន្តមានសន្ទុះរីកចម្រើនគួរជាទីមោទនៈ ដោយរក្សាបាននូវស្ថានភាពហិរញ្ញវត្ថុរឹងមាំ និងបង្កើនកិច្ចគាំពារដល់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ផងដែរ។ ក្នុងនោះដែរ ទីផ្សារធានារ៉ាប់រងកម្ពុជាទទួលបានកំណើនជាវិជ្ជមានប្រមាណ ៨% ក្នុងឆ្នាំ២០២០ និង ១០% ក្នុងឆ្នាំ២០២១។

### ៣.២.១. បុព្វលាភធានារ៉ាប់រង

បុព្វលាភធានារ៉ាប់រងបានបន្តកើនឡើងគួរឱ្យកត់សម្គាល់ ដោយក្នុងនោះបុព្វលាភធានារ៉ាប់រងដុលបានកើនឡើងពី ១៥៣ លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៧ ដល់ប្រមាណ ៣០០ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២១ និងមានកំណើនជាមធ្យមប្រមាណ ២០% ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ រីឯបុព្វលាភធានារ៉ាប់រងសុទ្ធបានកើនឡើងពី ៨៩ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៧ រហូតដល់ ២១៧ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២១។ ដោយឡែក គិតចាប់ពីឆ្នាំ២០១៨មក ឃើញថា អនុបាតរក្សាទុកបានកើនឡើងដល់ប្រមាណជាង ៧០% ដែលករណីនេះបង្ហាញថា ក្រុមហ៊ុនធានារ៉ាប់រងអាចមានលទ្ធភាព និងស្ថានភាពរឹងមាំក្នុងការរក្សាទុកហានិភ័យដោយខ្លួនឯង។

**រូបភាពទី៩÷** បុព្វលាភធានារ៉ាប់រង




*ប្រភព÷ និយ័តករធានារ៉ាប់រងកម្ពុជា*

អត្រាភាគទានធានារ៉ាប់រងក្នុងសេដ្ឋកិច្ច (Insurance Penetration) និងដង់ស៊ីតេធានារ៉ាប់រង (Insurance Density) គឺជារង្វាស់ពីរ ក្នុងចំណោមសូចនាករផ្សេងទៀត ដែលត្រូវបានប្រើប្រាស់ដើម្បីវាយតម្លៃកម្រិតនៃការអភិវឌ្ឍនៃវិស័យធានារ៉ាប់រងនៅក្នុងប្រទេសមួយ។ ក្នុងនោះ អត្រាភាគទានធានារ៉ាប់រងក្នុងសេដ្ឋកិច្ច ត្រូវបានគណនាជាភាគរយនៃបុព្វលាភធានារ៉ាប់រងធៀបទៅនឹងទិន្នផលក្នុងស្រុកសរុប (GDP) រីឯដង់ស៊ីតេធានារ៉ាប់រងត្រូវបានគណនាជាសមាមាត្រនៃបុព្វលាភធានារ៉ាប់រង ធៀបទៅនឹងចំនួនប្រជាជន (បុព្វលាភធានារ៉ាប់រងសម្រាប់មនុស្សម្នាក់)។

អត្រាភាគទានធានារ៉ាប់រងក្នុងសេដ្ឋកិច្ចកម្ពុជា បានកើនឡើងពីចំនួន ០,៦៩% នៅក្នុងឆ្នាំ២០១៧ ដល់ចំនួន ១,១១% ក្នុងឆ្នាំ២០២១ និងមានដង់ស៊ីតេធានារ៉ាប់រង កើនឡើងពីចំនួន ១០,០៦ ដុល្លារអាមេរិកក្នុង

ប្រជាជនម្នាក់ នៅក្នុងឆ្នាំ២០១៧ ដល់ចំនួន ១៨,៧៥ ដុល្លារអាមេរិកក្នុងប្រជាជនម្នាក់ នៅក្នុងឆ្នាំ២០២១។ ទោះបីជាទីផ្សារធានារ៉ាប់រងមានកំណើនគួរជាមោទនៈក៏ពិតមាន ប៉ុន្តែបើធៀបនឹងតំបន់ អត្រាភាគទានធានារ៉ាប់រងក្នុងសេដ្ឋកិច្ច និងដង់ស៊ីតេធានារ៉ាប់រង នៅមានកម្រិតទាបនៅឡើយ។

<u>**រូបភាពទី១០**</u>÷ អត្រាភាគទានធានារ៉ាប់រងក្នុងសេដ្ឋកិច្ច និងដង់ស៊ីតេធានារ៉ាប់រង




*ប្រភព÷ និយ័តករធានារ៉ាប់រងកម្ពុជា*

### ៣.២.១.១. ចំណែកទីផ្សារធានារ៉ាប់រង

ទីផ្សារធានារ៉ាប់រងអាយុជីវិត គឺជាទីផ្សារឈានមុខគេ ដោយក្តោបក្តាប់ចំណែកទីផ្សារធានារ៉ាប់រងរហូតដល់ ៥៧,៤% នៃទីផ្សារធានារ៉ាប់រងសរុប ក្នុងឆ្នាំ២០២១។ ចំណែកឯទីផ្សារធានារ៉ាប់រងទូទៅមានចំណែកទីផ្សារចំនួន ៤១,២% និងទីផ្សារធានារ៉ាប់រងខ្នាតតូច មានចំណែកទីផ្សារធានារ៉ាប់រងត្រឹមតែ ១,៤% នៃទីផ្សារធានារ៉ាប់រងសរុបប៉ុណ្ណោះ។

**រូបភាពទី១១**÷ ចំណែកទីផ្សារធានារ៉ាប់រងតាមប្រភេទធានារ៉ាប់រង




*ប្រភព÷ និយ័តករធានារ៉ាប់រងកម្ពុជា*

### ៣.២.១.២. បុព្វលាភធានារ៉ាប់រងបែងចែកតាមប្រព័ន្ធចែកចាយផលិតផលធានារ៉ាប់រង

ក្រុមហ៊ុនធានារ៉ាប់រង បានប្រើប្រាស់ប្រព័ន្ធចែកចាយផលិតផលធានារ៉ាប់រងដូចជា ក្រុមហ៊ុនជើងសាធានារ៉ាប់រង ភ្នាក់ងារធានារ៉ាប់រង បើងកាស្សូរេន បុគ្គលិកផ្នែកលក់ និងផ្សេងៗ ដើម្បីប្រមូលបុព្វលាភធានារ៉ាប់រង។ ក្នុងនោះដែរ បើងកាស្សូរេន ជាប្រព័ន្ធចែកចាយផលិតផលធានារ៉ាប់រងដែលប្រមូលបុព្វលាភធានារ៉ាប់រង បានច្រើនជាងគេ ក្នុងចំណោមប្រព័ន្ធចែកចាយផលិតផលធានារ៉ាប់រងទាំងអស់ ក្នុងឆ្នាំ២០២១ ដោយប្រមូលបុព្វលាភធានារ៉ាប់រងបានប្រមាណ ៣៩% នៃបុព្វលាភធានារ៉ាប់រងសរុប និងបន្ទាប់មក គឺការលក់ដោយផ្ទាល់ ដោយអាចប្រមូលបុព្វលាភធានារ៉ាប់រងបានចំនួន ២៣%។ រីឯ ភ្នាក់ងារធានារ៉ាប់រងអាចប្រមូលបុព្វលាភធានារ៉ាប់រងបានចំនួន ២០% នៃបុព្វលាភធានារ៉ាប់រងសរុប និងជើងសាធានារ៉ាប់រងអាចប្រមូលបុព្វលាភធានារ៉ាប់រងបានត្រឹមតែ ១០% ប៉ុណ្ណោះ។ គួរបញ្ជាក់ផងដែរថា ការកើនឡើងនៃការរកចំណូលបុព្វលាភធានា-

រ៉ាប់រងតាមរយៈប្រព័ន្ធចែកចាយផលិតផលធានារ៉ាប់រងប៉េងកាស្សួរេន គឺដោយសារមានការជួយជ្រោមជ្រែងពីរាជរដ្ឋាភិបាលក្នុងការរៀបចំលក្ខខណ្ឌសម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុក្នុងការធ្វើអាជីវកម្មប៉េងកាស្សួរេន ដើម្បីចូលរួមលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ តាមរយៈការបង្កើនលទ្ធភាពឱ្យសាធារណជនទទួលបានសេវាធានារ៉ាប់រងដោយមានភាពងាយស្រួល។

***រូបភាពទី១២***÷ បុព្វលាភធានារ៉ាប់រងបែងចែកតាមប្រព័ន្ធចែកចាយផលិតផលធានារ៉ាប់រង




*ប្រភព÷ និយ័តករធានារ៉ាប់រងកម្ពុជា*

## ៣.២.២. បុព្វលាភធានារ៉ាប់រងតាមប្រភេទផលិតផលធានារ៉ាប់រង

### ក. ផលិតផលធានារ៉ាប់រងទូទៅ

នៅក្នុងទីផ្សារធានារ៉ាប់រងកម្ពុជា ផលិតផលធានារ៉ាប់រងទូទៅត្រូវបានបែងចែកជា ៧ប្រភេទធំៗ រួមមាន យានយន្ត អគ្គីភ័យ នាវា វិស្វកម្ម គ្រោះថ្នាក់បុគ្គល សុខភាព និងផ្សេងៗ។ ក្នុងឆ្នាំ២០២១ ក្រុមហ៊ុនធានារ៉ាប់រងទូទៅមានចំណូលបុព្វលាភដុលសរុបប្រមាណ ១២៣,៥៨ លានដុល្លារអាមេរិក ក្នុងនោះផលិតផលធានារ៉ាប់រងអគ្គីភ័យមានចំណែកទីផ្សារខ្ពស់ជាងគេ គឺចំនួនប្រមាណ ៣០,៤% នៃបុព្វលាភដុលសរុប។ ផលិតផលធានារ៉ាប់រងដែលមានចំណែកភាគរយខ្ពស់បន្ទាប់ គឺផលិតផលធានារ៉ាប់រងសុខភាពមានចំនួនប្រមាណ ២១,៩% នៃបុព្វលាភដុល និងធានារ៉ាប់រងយានយន្តមានចំនួនប្រមាណ ១៧,៥% នៃបុព្វលាភដុល។ ដោយឡែក ផលិតផលធានារ៉ាប់រងដែលមានចំណែកទីផ្សារទាបជាងគេ គឺធានារ៉ាប់រងនាវាមានចំនួនប្រមាណ ៣,៤% នៃបុព្វលាភដុល ប៉ុណ្ណោះ ។

**<u>តារាងទី២</u>** ÷ បុព្វលាភធានារ៉ាប់រងតាមប្រភេទផលិតផលធានារ៉ាប់រងទូទៅ

| ប្រភេទផលិតផល | ២០២០ | | ២០២១ | | កំណើន | |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | % | ដុល្លារអាមេរិក | % | ដុល្លារអាមេរិក | % |
| យានយន្ត | ២១,០៤៧,៣១៣ | ១៨,៤ | ២១,៦១៥,៨៧១ | ១៧,៥ | ៥៦៨,៥៥៨ | ២,៧ |
| អគ្គីភ័យ | ៣៧,៥០៥,៩៩២ | ៣២,៨ | ៣៧,៥៨០,៧០១ | ៣០,៤ | ៧៤,៧០៩ | ០,២ |
| នាវា | ២,៨៨០,០៨៧ | ២,៥ | ៤,២៤១,៣១៧ | ៣,៤ | ១,៣៦១,២៣០ | ៤៧,៣ |
| វិស្វកម្ម | ៨,៥៣២,១០៩ | ៧,៥ | ៩,០៤៩,២០៦ | ៧,៣ | ៥១៧,០៩៧ | ៦,១ |
| គ្រោះថ្នាក់បុគ្គល | ៥,១០៤,២៥៣ | ៤,៥ | ៥,៧៣៩,០៣៨ | ៤,៦ | ៦៣៤,៧៨៥ | ១២,៤ |
| សុខភាព | ២១,៦០៥,០៣១ | ១៨,៩ | ២៧,០២០,៥៧៧ | ២១,៩ | ៥,៤១៥,៥៤៦ | ២៥,១ |
| ផ្សេងៗ | ១៧,៨១០,៤៩៣ | ១៥,៦ | ១៨,៣៣៥,៤៣៩ | ១៤,៨ | ៥២៤,៩៤៦ | ២,៩ |
| សរុប | ១១៤,៤៨៥,២៧៨ | ១០០,០ | ១២៣,៥៨២,១៤៩ | ១០០,០ | ៩,០៩៦,៨៧១ | ៧,៩ |

*ប្រភព÷ និយ័តករធានារ៉ាប់រងកម្ពុជា*

**<u>រូបភាពទី១៣</u>** ÷ ចំណែកទីផ្សារតាមប្រភេទផលិតផលធានារ៉ាប់រងទូទៅ ឆ្នាំ២០២១




*ប្រភព÷ និយ័តករធានារ៉ាប់រងកម្ពុជា*

### ខ.ផលិតផលធានារ៉ាប់រងអាយុជីវិត

ក្នុងឆ្នាំ២០២១ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត មានចំណូលបុព្វលាភដុលសរុបប្រមាណ ១៧២,១២ លានដុល្លារអាមេរិក ក្នុងនោះផលិតផលធានារ៉ាប់រងទាយជ្ជទានមានចំណែកទីផ្សារខ្ពស់ជាងគេ គឺចំនួនប្រមាណ ៨០% នៃបុព្វលាភដុល រីឯធានារ៉ាប់រងមួយជីវិតកាលមានចំនួន ០,៧% នៃបុព្វលាភដុល ដែលមានចំណែកទីផ្សារទាបជាងគេ។

**<u>តារាងទី៣</u>**÷បុព្វលាភធានារ៉ាប់រងតាមប្រភេទផលិតផលធានារ៉ាប់រងអាយុជីវិត

| ប្រភេទផលិតផល | ២០២០ | | ២០២១ | | កំណើនប្រចាំឆ្នាំ | |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | % | ដុល្លារអាមេរិក | % | ដុល្លារអាមេរិក | % |
| អាយុជីវិតមានកាលកំណត់ | ២១,៨៨២,៧៧០ | ១៤,៣ | ៣០,៤៨៤,៩២៩ | ១៧,៧ | ៨,៦០២,១៥៩ | ៣៩,៣ |
| មួយជីវិតកាល | ១,១០៨,៣៧១ | ០,៧ | ១,២២២,៨៦២ | ០,៧ | ១១៤,៤៩១ | ១០,៣ |
| ទាយជ្ជទាន | ១២៨,៧៩២,១៧៥ | ៨៤,០ | ១៣៧,៧២១,០៩៦ | ៨០,០ | ៨,៩២៨,៩២១ | ៦,៩ |
| ផ្សេងៗ | ១,៥៩០,៧៦៥ | ១.០ | ២,៦៩២,៥៧១ | ១,៦ | ១,១០១,៨០៦ | ៦៩,៣ |
| សរុប | ១៥៣,៣៧៤,០៨១ | ១០០,០ | ១៧២,១២១,៤៥៨ | ១០០,០ | ១៨,៧៤៧,៣៧៧ | ១២,២ |

*ប្រភព÷ និយ័តករធានារ៉ាប់រងកម្ពុជា*

**<u>រូបភាពទី១៤</u>**÷ ចំណែកទីផ្សារតាមផលិតផលធានារ៉ាប់រងអាយុជីវិត ឆ្នាំ២០២១




*ប្រភព÷ និយ័តករធានារ៉ាប់រងកម្ពុជា*

### គ. ផលិតផលធានារ៉ាប់រងខ្នាតតូច

ក្នុងឆ្នាំ២០២១ ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចមានចំណូលបុព្វលាភដុលសរុបប្រមាណ ៤,១៣ លានដុល្លារអាមេរិក ក្នុងនោះ ផលិតផលធានារ៉ាប់រងអាយុជីវិតមានកាលកំណត់មានចំណែកទីផ្សារខ្ពស់ជាងគេ គឺចំនួនប្រមាណ ៤០,១% នៃបុព្វលាភដុល និងផលិតផលធានារ៉ាប់រងគ្រោះថ្នាក់បុគ្គលមានចំនួនប្រមាណ ១៣,៨% នៃបុព្វលាភដុល ដែលមានចំណែកទីផ្សារទាបជាងគេ។

**<u>តារាងទី៤</u>**÷ បុព្វលាភធានារ៉ាប់រងតាមប្រភេទផលិតផលធានារ៉ាប់រងខ្នាតតូច

| ប្រភេទផលិតផល | ២០២០ | | ២០២១ | | កំណើនប្រចាំឆ្នាំ | |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | % | ដុល្លារអាមេរិក | % | ដុល្លារអាមេរិក | % |
| សុខភាព | ១,៨១៧,៤៥៧ | ៣៦,១ | ១,១១០,០៨៥ | ២៦,៩ | (៧០៧,៣៧២) | -៦៣,៧ |
| គ្រោះថ្នាក់បុគ្គល | ៧៦៤,៣៧៦ | ១៥,២ | ៥៦៩,៨១៣ | ១៣,៨ | (១៩៤,៥៦៣) | -៣៤,១ |
| អាយុជីវិតមានកាលកំណត់ | ១,៨៩០,២៣៩ | ៣៧,៥ | ១,៦៥៨,៥១៩ | ៤០,១ | (២៣១,៧២០) | -១៤,០ |
| ផ្សេងៗ | ៥៦២,៩២៦ | ១១,២ | ៧៩២,៩៨០ | ១៩,២ | ២៣០,០៥៤ | ២៩,០ |
| សរុប | ៥,០៣៤,៩៩៨ | ១០០,០ | ៤,១៣១,៣៩៧ | ១០០,០ | (៩០៣,៦០១) | -២២,០ |

*ប្រភព÷ និយ័តករធានារ៉ាប់រងកម្ពុជា*

**<u>រូបភាពទី១៥</u>**÷ ចំណែកទីផ្សារតាមផលិតផលធានារ៉ាប់រងខ្នាតតូចឆ្នាំ២០២១




*ប្រភព÷ និយ័តករធានារ៉ាប់រងកម្ពុជា*

### ៣.២.៣. សំណងធានារ៉ាប់រងដែលបានកើតឡើង

ក្នុងរយៈពេល៥ឆ្នាំនេះ សំណងធានារ៉ាប់រងដែលបានកើតឡើងសម្រាប់ទីផ្សារធានារ៉ាប់រងទូទៅ និងទីផ្សារធានារ៉ាប់រងខ្នាតតូចមានការប្រែប្រួលគួរឱ្យកត់សម្គាល់ ដោយក្នុងនោះសំណងធានារ៉ាប់រងដែលបានកើតឡើងខ្ពស់ជាងគេគឺនៅក្នុងឆ្នាំ២០១៩ មានចំនួន ១៣,៨៥លានដុល្លារអាមេរិក ជាមួយនឹងអនុបាតសំណងចំនួន ៣៣% និងបន្ទាប់មកគឺនៅក្នុងឆ្នាំ ២០២០ ដែលមានសំណងធានារ៉ាប់រងដែលបានកើតឡើងចំនួន ១៣,១៩ លានដុល្លារអាមេរិក ជាមួយនឹងអនុបាតសំណងចំនួន ៣១%។ ដោយឡែក នៅក្នុងឆ្នាំ២០២១ សំណងធានារ៉ាប់រងដែលបានកើតឡើងសម្រាប់ទីផ្សារធានារ៉ាប់រងទូទៅ និងទីផ្សារធានារ៉ាប់រងខ្នាតតូច បានធ្លាក់ចុះត្រឹមចំនួន ១១,៩៧ លានដុល្លារអាមេរិកប៉ុណ្ណោះ និងមានអនុបាតសំណងចំនួន ២៦%។ ចំណែកឯ សំណងធានារ៉ាប់រងដែលបានកើតឡើងសម្រាប់ទីផ្សារធានារ៉ាប់រងអាយុជីវិត ក៏បានកើនឡើងគួរអោយកត់សម្គាល់ផងដែរ ដោយបានកើនឡើងពី ២៦,២ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៧ ដល់ចំនួន ៨៦,៥ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២១ មានកំណើនជាមធ្យមប្រមាណ ៣៥% ក្នុងរយៈពេល៥ឆ្នាំនេះ។

**<u>រូបភាពទី១៦</u>**÷ សំណងធានារ៉ាប់រងដែលបានកើតឡើង សម្រាប់ក្រុមហ៊ុនធានារ៉ាប់រងទូទៅ និងធានារ៉ាប់រងខ្នាតតូច




*ប្រភព÷ និយ័តករធានារ៉ាប់រងកម្ពុជា*

**រូបភាពទី១៧**÷ សំណងធានារ៉ាប់រងដែលបានកើតឡើង សម្រាប់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត




*ប្រភព÷ និយ័តករធានារ៉ាប់រងកម្ពុជា*

## ៣.២.៤. លទ្ធផលប្រចាំឆ្នាំ

### ក. ចំណេញ ឬខាតពីការធានារ៉ាប់រង (Underwriting Profit/Loss)

ទោះបីជាកំណើននៃសំណងធានារ៉ាប់រងដែលបានកើតឡើង មានការកើនឡើងគួរឱ្យកត់សម្គាល់ក៏ពិតមែន ប៉ុន្តែក្រុមហ៊ុនធានារ៉ាប់រងនៅតែទទួលបានផលចំណេញពីអាជីវកម្មធានារ៉ាប់រង និងមានកំណើនពីមួយឆ្នាំទៅមួយឆ្នាំ។ ជាក់ស្តែង ចំណេញពីការធានារ៉ាប់រងបានកើនឡើងពី ៣៥,១ លានដុល្លារអាមេរិក ក្នុងឆ្នាំ ២០១៧ ដល់ចំនួន ៦០,៨ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២១ ដោយមានកំណើនជាមធ្យម ១៥% ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ដែលករណីនេះ បង្ហាញឱ្យឃើញនូវវឌ្ឍនភាពអាជីវកម្មគួរជាទីមោទនៈរបស់ទីផ្សារធានារ៉ាប់រងកម្ពុជា។

**រូបភាពទី១៨**÷ ចំណេញ ឬខាតពីការធានារ៉ាប់រង (Underwriting Profit/Loss)




*ប្រភព÷ និយ័តករធានារ៉ាប់រងកម្ពុជា*

### ខ. ចំណេញ ឬខាតមុនបង់ពន្ធ (Profit Before Tax)

ក្នុងចំណោមទីផ្សារធានារ៉ាប់រងទាំងបីប្រភេទនេះ មានតែទីផ្សារធានារ៉ាប់រងទូទៅទេដែលទទួលបានប្រាក់ចំណេញ ដោយក្នុងនោះប្រាក់ចំណេញមុនបង់ពន្ធ បានកើនឡើងពី ៨,៧៥ លានដុល្លារអាមេរិក ក្នុងឆ្នាំ ២០១៧ ដល់ ១១,៥ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២១ និងមានកំណើនជាមធ្យមចំនួន ៧% សម្រាប់រយៈពេលប្រាំឆ្នាំចុងក្រោយនេះ។ ចំណែកឯទីផ្សារធានារ៉ាប់រងអាយុជីវិតវិញ ឃើញថានៅមិនទាន់ទទួលបានប្រាក់ចំណេញនៅឡើយទេ ដោយសារអាជីវកម្មធានារ៉ាប់រងអាយុជីវិតទើបតែបង្កើតឡើងក្នុងឆ្នាំ២០១២ ប៉ុណ្ណោះ ដូច្នេះប្រាក់ចំណូលនៅមិនទាន់អាចរ៉ាប់រងចំណាយប្រតិបត្តិការបាននៅឡើយ។ រីឯទីផ្សារធានា-រ៉ាប់រងខ្នាតតូច ក៏នៅមិនទាន់ទទួលបានប្រាក់ចំណេញនៅឡើយទេ។

**រូបភាពទី១៩**÷ ចំណេញ ឬខាតមុនបង់ពន្ធ (Profit Before Tax)




*ប្រភព÷ និយ័តករធានារ៉ាប់រងកម្ពុជា*

**រូបភាពទី២០**÷ អនុបាតចំណេញធៀបនឹងទ្រព្យសកម្មតាមប្រភេទអាជីវកម្មធានារ៉ាប់រង




*ប្រភព÷ និយ័តករធានារ៉ាប់រងកម្ពុជា*

**រូបភាពទី២១**÷ អនុបាតចំណេញធៀបនឹងដើមទុនតាមប្រភេទអាជីវកម្មធានារ៉ាប់រង




*ប្រភព÷ និយ័តករធានារ៉ាប់រងកម្ពុជា*

## ៣.២.៥. ទ្រព្យសកម្មនៃទីផ្សារធានារ៉ាប់រង

វិស័យធានារ៉ាប់រង នៅតែរក្សាបាននូវភាពធន់ និងបានចូលរួមចំណែកយ៉ាងសកម្មក្នុងសេដ្ឋកិច្ចជាតិ។ ជាក់ស្តែងទ្រព្យសកម្មសរុប បានកើនឡើងពី ២៨៦ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៧ ដល់ចំនួន ៨៥១ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២១ ដោយមានកំណើនជាមធ្យម ៣១% ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ។ ទន្ទឹមនេះដែរ ចាប់តាំងពីឆ្នាំ២០១៨ មក ឃើញថាទីផ្សារធានារ៉ាប់រងអាយុជីវិតមានទ្រព្យសកម្មច្រើនជាងគេ និងបន្តកើនឡើងរហូតដល់ចំនួន ៥៥២ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២១។ រីឯទ្រព្យសកម្មរបស់ទីផ្សារធានារ៉ាប់រងទូទៅ ក៏បានកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ ក្នុងនោះទ្រព្យសកម្មបានកើនឡើងពី ១៣៩ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៧ ដល់ ចំនួន ២៩៤ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២១។ ចំណែកឯទ្រព្យសកម្មរបស់ទីផ្សារធានារ៉ាប់រងខ្នាតតូចបានថយចុះពី ៨ លានដុល្លារអាមេរិក ដល់ត្រឹម ៥ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២១។

**រូបភាពទី២២**÷ ទ្រព្យសកម្មនៃទីផ្សារធានារ៉ាប់រង




| | 2017 | 2018 | 2019 | 2020 | 2021 |
|---|---|---|---|---|---|
| ធានារ៉ាប់រងខ្នាតតូច | 8 | 6 | 6 | 6 | 5 |
| ធានារ៉ាប់រងទូទៅ | 139 | 190 | 247 | 276 | 294 |
| ធានារ៉ាប់រងអាយុជីវិត | 140 | 255 | 345 | 462 | 552 |

*ប្រភព÷ និយ័តករធានារ៉ាប់រងកម្ពុជា*

គិតត្រឹមឆ្នាំ២០២១ នេះ ទ្រព្យសកម្មសរុបនៃទីផ្សារធានារ៉ាប់រងមានចំនួន ៨៥១ លានដុល្លារអាមេរិក ក្នុងនោះ ៧០% នៃទ្រព្យសកម្មសរុប ជាទ្រព្យសកម្មវិនិយោគ, ៦% ជាទ្រព្យសកម្មពីការធានារ៉ាប់រងបន្ត, និង១៥% ទៀតជាទ្រព្យសកម្មផ្សេងៗ។

<u>**រូបភាពទី២៣**</u>÷ ប្រភេទទ្រព្យសកម្មនៃទីផ្សារធានារ៉ាប់រង




*ប្រភព÷ និយ័តករធានារ៉ាប់រងកម្ពុជា*

### ៣.២.៦. ទ្រព្យអកម្មធានារ៉ាប់រង

ទ្រព្យអកម្មធានារ៉ាប់រង គឺជាកាតព្វកិច្ចដែលក្រុមហ៊ុនធានារ៉ាប់រងត្រូវរក្សាទុក ដើម្បីធានាកាតព្វកិច្ចសំណងធានារ៉ាប់រង និងចំណាយដែលកើតឡើងពីកិច្ចសន្យាធានារ៉ាប់រង ដោយក្នុងនោះមាន ប្រាក់បម្រុងសម្រាប់បុព្វលាភមិនទាន់រកបាន, ប្រាក់បម្រុងសម្រាប់សំណងធានារ៉ាប់រងមិនទាន់ទូទាត់, ប្រាក់បម្រុងសម្រាប់ហានិភ័យមិនទាន់ផុតសុពលភាព និងប្រាក់បម្រុងតាមគណិតវិទ្យា។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ឃើញថាទ្រព្យ

អកម្មធានារ៉ាប់រង មានកំណើនគួរឱ្យកត់សម្គាល់ ដោយបានកើនឡើងពី ៦៩ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៧ ដល់ ៣៧៩ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២១ ដោយមានកំណើនជាមធ្យម ៥៣%។ រីឯទ្រព្យអកម្មសរុបបានកើនឡើងពី ១២៦ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៧ ដល់ ៤៨១ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២១ ដោយមានកំណើនជាមធ្យម ៤០% ក្នុងរយៈពេល៥ឆ្នាំនេះផងដែរ។

**រូបភាពទី២៤**÷ ទ្រព្យអកម្មធានារ៉ាប់រង




*ប្រភព÷ និយ័តករធានារ៉ាប់រងកម្ពុជា*

### ៣.២.៧. មូលធនផ្ទាល់របស់ទីផ្សារធានារ៉ាប់រង

មូលធនផ្ទាល់របស់ទីផ្សារធានារ៉ាប់រងមានកំណើនជាមធ្យម ២៣% ក្នុងរយៈពេល៥ឆ្នាំនេះ ដោយបានកើនឡើងដល់ ៣៦៩ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២១។ ក្នុងនោះដែរ គិតត្រឹមឆ្នាំ២០២១ នេះ មូលធនផ្ទាល់

របស់ទីផ្សារធានារ៉ាប់រងអាយុជីវិត បានកើនឡើងដល់ ១៨៨ លានដុល្លារអាមេរិក ខណៈដែល មូលធនផ្ទាល់របស់ទីផ្សារធានារ៉ាប់រងទូទៅ បានកើនឡើងដល់ ១៧៨ លានដុល្លារអាមេរិក និងទីផ្សារធានារ៉ាប់រងខ្នាតតូចមានប្រមាណ ៣ លានដុល្លារអាមេរិក។

**<u>រូបភាពទី២៥</u>**÷ មូលធនផ្ទាល់របស់ទីផ្សារធានារ៉ាប់រង




*ប្រភព÷ និយ័តករធានារ៉ាប់រងកម្ពុជា*

## ៣.៣. ការបណ្តុះបណ្តាលវិជ្ជាជីវៈធានារ៉ាប់រង

ការបណ្តុះបណ្តាលវិជ្ជាជីវៈ បានដើរតួនាទីជាស្ពានរវាងក្រុមហ៊ុនធានារ៉ាប់រងនិងអតិថិជន និងបានចូលរួមចំណែកយ៉ាងសកម្មក្នុងការជំរុញកំណើនទីផ្សារធានារ៉ាប់រងនៅកម្ពុជា ប៉ុន្តែចាប់តាំងពីវិស័យធានារ៉ាប់រងនៅកម្ពុជាបានចាប់ផ្តើមឡើងវិញក្នុងឆ្នាំ១៩៩០ មក ឃើញថាការបណ្តុះបណ្តាលវិជ្ជាជីវៈធានារ៉ាប់រងនៅមានភាពស្រពិចស្រពិលនៅឡើយ ពោលគឺមិនទាន់មានការបណ្តុះបណ្តាលជាផ្លូវការនៅកម្រិតឧត្តមសិក្សា ឬការបណ្តុះបណ្តាលជាជំនាញឱ្យបានត្រឹមត្រូវ ឬកម្មវិធីសិក្សាច្បាស់លាស់ប្រកបដោយគុណភាពដែលអាចធានានិរន្តរភាព និងទទួលស្គាល់ជាផ្លូវការបាននោះទេ។ ជាក់ស្តែងចាប់តាំងពីឆ្នាំ២០០៥ មក ក្រុមហ៊ុនធានារ៉ាប់រងទូទៅមួយចំនួនបានប្រឹងប្រែងបណ្តុះបណ្តាលបុគ្គលិកក្រុមហ៊ុនរបស់ខ្លួន តាមរយៈការសិក្សាពីចម្ងាយ (online learning) ស្តីពីការធានារ៉ាប់រង ពីប្រទេសក្នុងតំបន់ ឬអន្តរជាតិ រួមមាន÷ កិច្ចសហការជាមួយវិទ្យាស្ថានធានារ៉ាប់រងម៉ាឡេស៊ី (Malaysian Insurance Institute), សឹង្ហបុរី, អូស្ត្រាលី ជាដើម។ ជាលទ្ធផល មានបេក្ខភាពតិចតួចណាស់ ដែលបានបញ្ចប់វគ្គសិក្សាទាំងនេះ។ បន្ថែមពីនេះ ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា “កម្ពុជារី” បាន និងកំពុងបន្តកិច្ចសហការជាមួយវិទ្យាស្ថានធានារ៉ាប់រងម៉ាឡេស៊ី ក្នុងការបណ្តុះបណ្តាលជាវគ្គខ្លីៗពាក់ព័ន្ធនឹងការធានារ៉ាប់រងទូទៅដល់បុគ្គលិកមកពីបណ្តាក្រុមហ៊ុនធានារ៉ាប់រងជាដៃគូ និងស្ថាប័នពាក់ព័ន្ធផ្សេងៗ ប៉ុន្តែលទ្ធផលទទួលបានពីវគ្គបណ្តុះបណ្តាលនេះនៅមានកម្រិតនៅឡើយ។

ចាប់តាំងពីការកកើតនៃការធានារ៉ាប់រងអាយុជីវិតនៅឆ្នាំ២០១២ មក ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតត្រូវបានអនុញ្ញាតឱ្យផ្តល់ការបណ្តុះបណ្តាលផ្ទៃក្នុង លើចំណេះដឹងស្តីពីផលិតផលធានារ៉ាប់រងអាយុជីវិត ដល់បុគ្គលិកផ្នែកលក់ ឬ អ្នកផ្តល់ប្រឹក្សាធានារ៉ាប់រង។ ដោយមើលឃើញពីកង្វះខាតនេះ និយ័តករធានារ៉ាប់រងកម្ពុជា បានចេញនូវសេចក្តីណែនាំលេខ ០០២ នធក/សណ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២១ ស្តីពីការបណ្តុះបណ្តាលវិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រង ក្នុងគោលបំណងបង្កើតជាស្តង់ដាររួមមួយ ដើម្បីបង្កើនគុណភាពនៃការបណ្តុះបណ្តាលវិជ្ជាជីវៈធានារ៉ាប់រង ជាពិសេសវិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ដោយផ្អែកតាមសេចក្តីណែនាំខាងលើ វគ្គបណ្តុះបណ្តាលត្រូវបានបែងចែកជាពីរ÷ ទីមួយ វគ្គបណ្តុះបណ្តាលមូលដ្ឋានដែលមានបួនមុខវិជ្ជា និងត្រូវមានរយៈពេល៨ម៉ោង និងទីពីរ វគ្គបណ្តុះបណ្តាលឯកទេស គឺសម្រាប់

បុគ្គលដែលទទួលបានវិញ្ញាបនបត្របញ្ចប់វគ្គបណ្តុះបណ្តាលមូលដ្ឋាន ហើយមានបំណងប្រកបអាជីពជាភ្នាក់ងារធានារ៉ាប់រងឱ្យក្រុមហ៊ុនធានារ៉ាប់រងណាមួយ។ ក្នុងករណីដែលក្រុមហ៊ុនណាមានបំណង ផ្តល់វគ្គបណ្តុះបណ្តាលមូលដ្ឋាន និង/ឬឯកទេស ក្រុមហ៊ុនត្រូវរៀបចំកម្មវិធីសិក្សា ឯកសារ និងវិធីសាស្ត្របង្រៀននិងបែបបទនៃការប្រឡង គំរូវិញ្ញាបនបត្របញ្ជាក់ការសិក្សា និងបញ្ជីឈ្មោះបុគ្គលទទួលខុសត្រូវវគ្គបណ្តុះបណ្តាល ដើម្បីស្នើសុំការឯកភាពពីនិយ័តករធានារ៉ាប់រងកម្ពុជា មុននឹងផ្តល់វគ្គបណ្តុះបណ្តាល។ ជាមួយគ្នានេះ និយ័តករធានារ៉ាប់រងកម្ពុជា បានផ្តល់ការឯកភាពលើឯកសារវគ្គបណ្តុះបណ្តាលរបស់ក្រុមហ៊ុនសរុបមានចំនួន ២០ ដែលក្នុងនោះក្រុមហ៊ុនធានារ៉ាប់រងទូទៅមានចំនួន ៤ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតមានចំនួន ១១ និងក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចមានចំនួន ៥។

រីឯ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈវិញ មានក្រុមហ៊ុនមួយចំនួនបានផ្តល់ការបណ្តុះបណ្តាលផ្ទៃក្នុង ឬការសិក្សាពីចម្ងាយលើមុខវិជ្ជាមួយចំនួនដូចជា៖ ជំនាញគណនាតម្លៃបុព្វលាភធានារ៉ាប់រង និងមានកិច្ចសហការជាមួយនឹង Life Office Management Association (LOMA) របស់សហរដ្ឋអាមេរិកក្នុងការបណ្តុះបណ្តាលជំនាញវិភាគហានិភ័យធានារ៉ាប់រងអាយុជីវិត គោលការណ៍អនុលោមភាពនៃវិស័យធានារ៉ាប់រង និងការបំរើសេវាអតិថិជន។

ដោយសង្កេតឃើញថា ចំណេះដឹង និងកម្រិតជំនាញស្តីពីការធានារ៉ាប់រងនៅមានកម្រិត និងដើម្បីរួមចំណែកកសាងធនធានមនុស្សនៅកម្ពុជា សំដៅបំពេញបាននូវតម្រូវការជំនាញពាក់ព័ន្ធនឹងការធានារ៉ាប់រង និយ័តករធានារ៉ាប់រងកម្ពុជាបានដាក់ចេញនូវផែនការសកម្មភាពសំខាន់ៗ ដូចមាននៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជា ២០២១-២០៣០ ដូចជា៖

- បន្តយកចិត្តទុកដាក់ក្នុងការជំរុញឱ្យមានវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈធានារ៉ាប់រង ដែលត្រូវបានរៀបចំឱ្យមានជាផ្លូវការជាជំហានៗ តាមកម្រិតធនធានហិរញ្ញវត្ថុរបស់និយ័តករធានារ៉ាប់រងកម្ពុជា និងតម្រូវការជាក់ស្តែងនៃទីផ្សារ។ លើសពីនេះទៀត និយ័តករធានារ៉ាប់រងកម្ពុជា នឹងផ្តល់ការគាំទ្រយ៉ាងពេញទំហឹងដល់សមាគមធានារ៉ាប់រងកម្ពុជា ក្នុងការរៀបចំឱ្យមានស្តង់ដាររួមនៃ “ឯកសារបង្រៀនវគ្គបណ្តុះបណ្តាលមូលដ្ឋានសម្រាប់ភ្នាក់ងារធានារ៉ាប់រង និងបុគ្គលិកលក់របស់ក្រុមហ៊ុនធានារ៉ាប់រង” ក្នុងគោលបំណងផ្តល់មគ្គុទ្ទេសក៍ អំពីខ្លឹមសារ និងរបៀបប្រើប្រាស់ឯកសារបង្រៀន

គោលនេះ សម្រាប់ប្រើប្រាស់ជាផ្លូវការក្នុងក្រុមហ៊ុនធានារ៉ាប់រងនីមួយៗឱ្យមានប្រសិទ្ធភាព និងសង្គតិភាព ក្នុងការបង្រៀនភ្នាក់ងារធានារ៉ាប់រង និងបុគ្គលិកលក់របស់ខ្លួន។ ជាមួយគ្នានេះដែរ និយ័តករធានារ៉ាប់រងកម្ពុជា នឹងផ្តល់ការគាំទ្រ និងលើកទឹកចិត្តឱ្យសមាគមធានារ៉ាប់រងកម្ពុជា រៀបចំឱ្យមានសិក្ខាសាលា ដើម្បីណែនាំដល់គ្រូបង្គោលរបស់ក្រុមហ៊ុនធានារ៉ាប់រងទាំងអស់អំពីខ្លឹមសារឯកសារគោលនេះ ដើម្បីពួកគាត់យកទៅបង្ហាត់បង្ហាញដល់បុគ្គលិកផ្នែកលក់, អ្នកប្រឹក្សាធានារ៉ាប់រង, និងភ្នាក់ងារជារូបវន្តបុគ្គលជាដើម

- សហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីពង្រឹងកម្មវិធីសិក្សាមូលដ្ឋានសម្រាប់ជំនាញធានារ៉ាប់រងក្នុងកម្រិតឧត្តមសិក្សា
- សហការរៀបចំជាមួយសមាគមវិជ្ជាជីវៈធានារ៉ាប់រង ដើម្បីសិក្សា និងរៀបចំវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈជើងសា និងភ្នាក់ងារធានារ៉ាប់រង
- សិក្សា និងរៀបចំផែនការបង្កើតសាលា ឬវិទ្យាស្ថានជាតិធានារ៉ាប់រង ដើម្បីផ្តល់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងវិស័យធានារ៉ាប់រង
- រៀបចំកែសម្រួលបទប្បញ្ញត្តិស្តីពីការផ្តល់អាជ្ញាបណ្ណ ឬការចុះបញ្ជីអន្តរការីធានារ៉ាប់រងក្នុងការទទួលស្គាល់លទ្ធផលសិក្សាក្រោមវគ្គបណ្តុះបណ្តាលផ្លូវការដែលបានរៀបចំ និងជំរុញការរៀបចំបង្កើតសមាគមជើងសាធានារ៉ាប់រងកម្ពុជា។

## ៣.៤. ការធានារ៉ាប់រងជាកាតព្វកិច្ច

ការធានារ៉ាប់រងជាកាតព្វកិច្ច ជាធានារ៉ាប់រងដែលតម្រូវដោយច្បាប់ជាធរមាន ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលណាដែលប្រកបអាជីវកម្មមួយចំនួននៅក្នុងព្រះរាជាណាចក្រកម្ពុជា។ បច្ចុប្បន្ននេះ កម្ពុជាមានការធានារ៉ាប់រងជាកាតព្វកិច្ចចំនួន ៣ ប្រភេទសំខាន់ៗគឺ÷ ១). កាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន ២). កាតព្វកិច្ចធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ និង ៣). កាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត ឬធានារ៉ាប់រងតតិយជន។ ការអនុវត្តលើការធានារ៉ាប់រងជាកាតព្វកិច្ច ផ្អែកលើឯកសារគតិយុត្តមួយចំនួន ដូចជា÷

- អនុក្រឹត្យលេខ២៧៥ អនក្រ.បក ស្តីពីការធានារ៉ាប់រង ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ត្រង់ជំពូកទី៤ ស្តីពីប្រភេទធានារ៉ាប់រងជាកាតព្វកិច្ច
- ប្រកាសអន្តរក្រសួងលេខ ៦៥៥ ប្រក.សហវ.ជនស.មផ ស្តីពីកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០២
- ប្រកាសអន្តរក្រសួងលេខ ៦៥៤ ប្រក.សហវ.សក.ទច.មផ ស្តីពីកាតព្វកិច្ចធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០២
- ប្រកាសអន្តរក្រសួងលេខ ៦៥៣ ប្រក.សហវ.សក.ទច.មផ ស្តីពីកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត ឬធានារ៉ាប់រងតតិយជន ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០២
- ប្រកាសលេខ ០០២ សហវ.ប្រក ស្តីពីលតាបត្រធានារ៉ាប់រងយានយន្តជាកាតព្វកិច្ច ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០០៦។

ផ្អែកតាមការកែសម្រួលរចនាសម្ព័ន្ធស្ថាប័នទទួលបន្ទុក តាមរយៈការបង្កើតឱ្យមាននូវនិយ័តករធានារ៉ាប់រងកម្ពុជា ប្រការនេះមានភាពចាំបាច់ក្នុងការពិនិត្យឡើងវិញ ដើម្បីកែសម្រួលលិខិត និងឯកសារគតិយុត្តពាក់ព័ន្ធមួយចំនួន សំដៅសម្រួលដល់ការអនុវត្តប្រកាស និងអនុក្រឹត្យខាងលើ។ ក្នុងន័យនេះ ក្រុមការងារនៃនិយ័តករធានារ៉ាប់រងកម្ពុជា បានធ្វើការសិក្សា និងវិភាគលើចំណុចដែលត្រូវកែសម្រួល និងបានដាក់ចេញនូវផែនការសកម្មភាពការងារសម្រាប់អនុវត្តក្នុងឆ្នាំ២០២២ ដើម្បីធ្វើវិសោធនកម្មលើប្រកាសស្តីពី "ការបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីអនុវត្តប្រកាសអន្តរក្រសួង ស្តីពីកាតព្វកិច្ចធានារ៉ាប់រង"។

## ក. កាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត ឬធានារ៉ាប់រងតតិយជន

បុព្វលាភដុលនៃកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត ឬធានារ៉ាប់រងតតិយជន មានការកើនឡើងជាមធ្យម ៥,០៩% និងចំនួនកិច្ចសន្យាធានារ៉ាប់រងក៏មានការកើនឡើងផងដែរប្រមាណ ៧,២៥% ក្នុងចន្លោះឆ្នាំ២០១៧ ដល់ឆ្នាំ២០២១។ ក្នុងនោះ បុព្វលាភដុលនៃកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត ឬធានារ៉ាប់រងតតិយជន បានកើនពីប្រមាណ ៤,៣ លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៧ ដល់ប្រមាណ ៥,២ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២១។

**<u>រូបភាពទី២៦</u>**÷ កាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត ឬធានារ៉ាប់រងតតិយជន




*ប្រភព÷ និយ័តករធានារ៉ាប់រងកម្ពុជា*

## ខ. កាតព្វកិច្ចធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ

បុព្វលាភដុលនៃកាតព្វកិច្ចធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ មានការកើនឡើងជាមធ្យម ៣៩,៣៣% និងចំនួនកិច្ចសន្យាធានារ៉ាប់រងក៏មានការកើនឡើងផងដែរប្រមាណ ៥៦,២៦% ក្នុងចន្លោះឆ្នាំ២០១៧ ដល់ឆ្នាំ២០២១។ ក្នុងនោះ បុព្វលាភដុលនៃកាតព្វកិច្ចធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ បានកើនពីប្រមាណ ១,០៥ លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៧ ដល់ប្រមាណ ៣,២ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២១។

**<u>រូបភាពទី២៧</u>**÷ កាតព្វកិច្ចធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ




*ប្រភព÷ និយ័តករធានារ៉ាប់រងកម្ពុជា*

### គ. ភាគពួកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន

បុព្វលាភដុលនៃកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន មានការកើនឡើងជាមធ្យម ២០,៨០% និងចំនួនកិច្ចសន្យាធានារ៉ាប់រងក៏មានការកើនឡើងផងដែរប្រមាណ ២៩,១៩% ក្នុងចន្លោះឆ្នាំ២០១៧ ដល់ឆ្នាំ២០២១។ ក្នុងនោះ បុព្វលាភដុលនៃកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន បានកើនពីប្រមាណ ៣,៧ លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៧ ដល់ប្រមាណ ៧,៥ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២១។

<u>**រូបភាពទី២៨**</u>÷ កាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន




*ប្រភព÷ និយ័តករធានារ៉ាប់រងកម្ពុជា*

## ៣.៥. ការលើកកម្ពស់ការយល់ដឹងសាធារណៈ

ការផ្សព្វផ្សាយ និងការអប់រំជាសាធារណៈ មានសារៈសំខាន់ណាស់ក្នុងការរួមចំណែកអភិវឌ្ឍវិស័យធានារ៉ាប់រងនៅកម្ពុជា។ ចាប់តាំងពីការកកើតសកម្មភាពធានារ៉ាប់រងក្នុងអំឡុងទសវត្សរ៍ទី៩០ មកដល់បច្ចុប្បន្ន ការយល់ដឹងរបស់សាធារណជនក្នុងវិស័យធានារ៉ាប់រងមានភាពល្អប្រសើរជាបន្តបន្ទាប់ ដោយបានឆ្លុះបញ្ចាំងតាមរយៈការកើនឡើងនៃទំហំបុព្វលាភក្នុងសេដ្ឋកិច្ចកម្ពុជា និងការប្រើប្រាស់ធានារ៉ាប់រងរបស់ប្រជាពលរដ្ឋជារួម (ដង់ស៊ីតេធានារ៉ាប់រង)។

ក្នុងឆ្នាំ២០២១ **ន.ធ.ក.** បានដាក់ចេញនូវសកម្មភាពអាទិភាពជាច្រើន ក្នុងនោះក៏មាន ការលើកកម្ពស់ការយល់ដឹងសាធារណៈអំពីធានារ៉ាប់រងផងដែរ ដែលមានដូចជា ការចូលរួមផ្សព្វផ្សាយនិងការអប់រំជាសាធារណៈតាមរយៈបណ្តាញទូរទស្សន៍ជាតិកម្ពុជា (**ទ.ទ.ក.**) ដែលទទួលបានការគាំទ្រពីបណ្តាសាធារណជនទូទៅជាច្រើន។ តាមរយៈការផ្សព្វផ្សាយលើទូរទស្សន៍ជាតិកម្ពុជា **ន.ធ.ក.** បានផ្តល់នូវចំណេះដឹងពាក់ព័ន្ធនឹងប្រធានបទមួយចំនួនដូចជា÷ ១). សាវតារនៃនិយ័តករធានារ៉ាប់រងកម្ពុជា ២). ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិស្តីពីការធានារ៉ាប់រង ៣). ប្រភេទផលិតផលធានារ៉ាប់រងនៅព្រះរាជាណាចក្រកម្ពុជា និង ៤). ការធានារ៉ាប់រងជាកាតព្វកិច្ច។

<u>**រូបភាពទី២៩**</u>÷ កិច្ចសម្ភាសន៍រវាង ឯកឧត្តម **ប៊ូ ច័ន្ទភិរុ** អគ្គនាយក នៃនិយ័តករធានារ៉ាប់រងកម្ពុជា ជាមួយទូរទស្សន៍ជាតិកម្ពុជា ក្រោមប្រធានបទ “សាវតារនៃនិយ័តករធានារ៉ាប់រងកម្ពុជា”



**<u>រូបភាពទី៣០</u>**÷ កិច្ចសម្ភាសន៍រវាង លោកស្រីបណ្ឌិត **ហោ សុវឌ្ឍនា** អគ្គនាយករង ជាមួយ ទ.ទ.ក. ក្រោមប្រធានបទ “ក្របខណ្ឌច្បាប់ និងបទបញ្ញត្តិស្តីពីការធានារ៉ាប់រង”



**<u>រូបភាពទី៣១</u>**÷ កិច្ចសម្ភាសន៍រវាង លោក **ទូច ម៉េងឡេង** ប្រធាននាយកដ្ឋាន ជាមួយ ទ.ទ.ក. ក្រោមប្រធានបទ “ប្រភេទផលិតផលធានារ៉ាប់រងនៅទីផ្សារកម្ពុជា”



**<u>រូបភាពទី៣២</u>**÷ កិច្ចសម្ភាសន៍រវាង លោក **ទ៉ា ទិដ្ឋា** ប្រធាននាយកដ្ឋាន ជាមួយ ទ.ទ.ក. ក្រោមប្រធានបទ “ការធានារ៉ាប់រងជាកាតព្វកិច្ច”



ទោះបីជាយ៉ាងណាក៏ដោយ **ន.ធ.ក.** បានរៀបចំផែនការសកម្មភាពការងាររបស់ខ្លួនសម្រាប់អនុវត្តបន្តក្នុងឆ្នាំ២០២២ ដើម្បីធ្វើការផ្សព្វផ្សាយពីវិស័យធានារ៉ាប់រង តាមរយៈសកម្មភាពការងារមួយចំនួនដូចខាងក្រោម÷

- រៀបចំសិក្ខាសាលាស្តីពី អត្ថប្រយោជន៍នៃការធានារ៉ាប់រងជាកាតព្វកិច្ច នៅតាមបណ្តាខេត្តគោលដៅមួយចំនួននៃព្រះរាជាណាចក្រកម្ពុជា
- រៀបចំកម្មវិធីចែករំលែកចំណេះដឹងធានារ៉ាប់រង ក្នុងទម្រង់ជាការចេញផ្សាយនូវអត្ថបទខ្លីៗជុំវិញវិស័យធានារ៉ាប់រងនៅកម្ពុជា តាមបណ្តាញផ្សព្វផ្សាយផ្សេងៗដូចជា គេហទំព័រ និងបណ្តាញសង្គមរបស់ **ន.ធ.ក.**
- រៀបចំផលិតខ្សែវីដេអូស្តីពីការធានារ៉ាប់រងជាកាតព្វកិច្ច សម្រាប់ធ្វើការផ្សព្វផ្សាយលើកញ្ចក់ទូរទស្សន៍ បណ្តាញសង្គម និងគេហទំព័ររបស់ **ន.ធ.ក.**
- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងគោលដៅ ពិនិត្យលទ្ធភាពដាក់បញ្ចូលមុខវិជ្ជាធានារ៉ាប់រង ទៅក្នុងកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រ។

# ផ្នែកទី៤: កិច្ចសហប្រតិបត្តិការ

## ៤.១. កិច្ចសហប្រតិបត្តិការក្នុងប្រទេស

❖ **ក្របខណ្ឌការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ**

**ន.ធ.ក.** បានសម្របសម្រួលអញ្ជើញថ្នាក់ដឹកនាំនៃក្រុមហ៊ុនធានារ៉ាប់រង និងក្រុមហ៊ុនជើងសាធានារ៉ាប់រងទាំងអស់ចូលរួមកម្មវិធីសិក្ខាសាលាស្ដីពី “ការវាយតម្លៃហានិភ័យលើការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ” ដែលរៀបចំដោយក្រសួងមហាផ្ទៃ កាលពីថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ តាមរយៈប្រព័ន្ធវីដេអូអនឡាញ។ បន្ថែមពីនេះ **ន.ធ.ក.** បានរៀបចំផែនការកម្មវិធីបណ្ដុះបណ្ដាល ដើម្បីពង្រឹងសមត្ថភាពចំណេះដឹងមន្ត្រីជំនាញ និងពង្រឹងចំណេះដឹងបុគ្គលរាយការណ៍ក្រោមសមត្ថកិច្ចរបស់ **ន.ធ.ក.** អំពីច្បាប់ស្ដីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ សម្រាប់អនុវត្តក្នុងឆ្នាំ២០២២។

ដើម្បីចូលរួមដំឡើងចំណាត់ថ្នាក់ល្អប្រសើរ ក្នុងក្របខណ្ឌការងារប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ **ន.ធ.ក.** បានរៀបចំកែសម្រួលប្រកាស និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការផ្ដល់អាជ្ញាបណ្ណ ដល់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត និងក្រុមហ៊ុនធានារ៉ាប់រងទូទៅ ស្របតាមអនុសាសន៍របស់ក្រុមការងារហិរញ្ញវត្ថុ (FATF) ដោយតម្រូវឱ្យមានភ្ជាប់មកនូវលិខិតថ្កោលទោស ធ្វើជាឯកសារតម្រូវមួយក្នុងចំណោមឯកសារតម្រូវដទៃទៀត សម្រាប់ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ។

**ន.ធ.ក.** ក៏បានចូលរួមផ្ដល់មតិយោបល់លើសេចក្ដីព្រាងនៃ “សេចក្ដីណែនាំស្ដីពីការត្រួតពិនិត្យផ្ទៃក្នុងសម្រាប់បុគ្គលរាយការណ៍” ដែលត្រូវបានរៀបរៀងឡើងដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។

❖ **ការបង្កើតក្រុមការងារអន្តរក្រសួងដើម្បីអនុវត្តប្រកាសអន្តរក្រសួងស្ដីពីកាតព្វកិច្ចធានារ៉ាប់រង**

នាយកដ្ឋានស្រាវជ្រាវ បណ្ដុះបណ្ដាល និងសហប្រតិបត្តិការ នៃ **ន.ធ.ក.** បានរៀបចំកិច្ចប្រជុំផ្ទៃក្នុងនាយកដ្ឋានចំនួន ០៣ លើក ក្នុងគោលបំណងពិភាក្សាលើការកែសម្រួលសមាសភាព និង តួនាទីនិងភារកិច្ចនៃក្រុមការងារអន្តរក្រសួង នៅក្នុងប្រកាសលេខ៧៥១ សហវ.ប្រក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០ ស្ដីពី “ការ

បង្កើតក្រុមការងារអន្តរក្រសួងដើម្បីអនុវត្តប្រកាសអន្តរក្រសួងស្តីពីកាតព្វកិច្ចធានារ៉ាប់រង” ដើម្បីដាក់ជូនថ្នាក់ដឹកនាំ ពិនិត្យ ណែនាំ និងសម្រេចដ៏ខ្ពង់ខ្ពស់លើសេចក្តីព្រាងប្រកាសខាងលើ ។

❖ **កិច្ចប្រជុំគណៈកម្មាធិការជាតិសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់ (NTTCC)**

**ន.ធ.ក.** បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការជាតិសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១។ កិច្ចប្រជុំត្រូវបានរៀបចំឡើងក្នុងគោលបំណងពិភាក្សាលើរបាយការណ៍សង្ខេប ស្តីពីការអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់ព្រំដែន រួមមានកិច្ចព្រមព្រៀងទ្វេភាគី, កិច្ចព្រមព្រៀងត្រីភាគីកម្ពុជា-ឡាវ-វៀតណាម (CLV), កិច្ចព្រមព្រៀងសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់ក្នុងមហាអនុតំបន់មេគង្គ (GMS-CBTA) និងកិច្ចព្រមព្រៀងសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់ក្នុងតំបន់អាស៊ាន (ASEAN Transport Facilitation Agreement) និងពិភាក្សាអំពីអនុស្សរណៈនៃការយោគយល់ (MOU) ស្តីពីការតម្លើងកូតាយានយន្តដឹកជញ្ជូនឆ្លងកាត់កម្ពុជា-វៀតណាម ដោយបានពិនិត្យលើពង្រាង MOU ចុងក្រោយបន្ទាប់ពីមានការកែសម្រួលពីភាគីវៀតណាម។

<u>**រូបភាពទី៣៣**</u>÷ កិច្ចប្រជុំគណៈកម្មាធិការជាតិសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់ (NTTCC)



## ៤.២. កិច្ចសហប្រតិបត្តិការក្រៅប្រទេស

❖ **កិច្ចប្រជុំនិយ័តករធានារ៉ាប់រងអាស៊ាន (AIRM)**

**<u>រូបភាពទី៣៤</u>÷** កិច្ចប្រជុំនិយ័តករធានារ៉ាប់រងអាស៊ាន លើកទី២៤ (24th AIRM)




<u>រូបភាពទី៣៥</u>÷ កិច្ចប្រជុំ AIRM-AIC Joint Plenary



កិច្ចប្រជុំនិយ័តករធានារ៉ាប់រងអាស៊ាន លើកទី២៤ (24th AIRM) ដែលជាវេទិកាប្រចាំឆ្នាំសម្រាប់និយ័តករធានារ៉ាប់រងដែលមានតួនាទីត្រួតពិនិត្យវិស័យធានារ៉ាប់រង មកពីបណ្តាប្រទេសសមាជិកអាស៊ានទាំងដប់ដើម្បីចែករំលែកគំនិត និងព័ត៌មានទាក់ទងនឹងការអភិវឌ្ឍចុងក្រោយនៃវិស័យធានារ៉ាប់រងក្នុងតំបន់។ កិច្ចប្រជុំនេះត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី២៧ ដល់ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ តាមរយៈប្រព័ន្ធវីដេអូអនឡាញ និងដឹកនាំដោយប្រធាននៃកិច្ចប្រជុំដែលជា តំណាងអាជ្ញាធររូបិយវត្ថុសិង្ហបុរី (MAS) និងមានការចូលរួមពីបណ្តាប្រទេសជាសមាជិកអាស៊ានទាំងអស់។ ជាមួយគ្នានេះ ប្រតិភូកម្ពុជាដឹកនាំដោយ **ឯកឧត្តម ម៉ូ ច័ន្ទតិរ៉ូ** អគ្គនាយកនៃ **ន.ធ.ក.** ក៏បានចូលរួមក្នុងកិច្ចប្រជុំខាងលើដើម្បីចែករំលែក និងពិភាក្សាអំពីបញ្ហាប្រឈម និងកាលានុវត្តភាពសម្រាប់វិស័យធានារ៉ាប់រងផងដែរ។

❖ **ហិរញ្ញប្បទានហានិភ័យគ្រោះមហន្តរាយ និងការធានារ៉ាប់រងអាស៊ាន ដំណាក់កាលទី២ (ADRFI-2)**

**ន.ធ.ក.** បានបន្តកិច្ចសហប្រតិបត្តិការលើគម្រោងហិរញ្ញប្បទានហានិភ័យគ្រោះមហន្តរាយ និងការធានារ៉ាប់រងអាស៊ានដំណាក់កាលទី២ ដែលគម្រោងនេះមានសសរស្តម្ភចំនួនបី រួមមានការវាយតម្លៃហានិភ័យ (Risk Assessment), ការប្រឹក្សាហានិភ័យ (Risk Advisory) និងការកសាងសមត្ថភាព (Capacity Building)។

<u>**រូបភាពទី៣៦**</u>÷ កិច្ចប្រជុំទ្វេភាគីជាមួយ សកលវិទ្យាល័យណានយ៉ាង ស្តីពីហិរញ្ញប្បទាន
ហានិភ័យគ្រោះមហន្តរាយ និងការធានារ៉ាប់រងអាស៊ាន ដំណាក់កាលទី២ (ADRFI-2)
ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១



តាមរយៈកិច្ចសហប្រតិបត្តិការនេះ **ន.ធ.ក.** បានសម្របសម្រួលផ្តល់ទិន្នន័យស្តីពី Insurance Exposure Data និង Economic Loss Data របស់កម្ពុជាជូនក្រុមការងារដើម្បីគាំទ្រការវិភាគលើទិន្នន័យទាំងនេះ សម្រាប់ការងារវាយតម្លៃហានិភ័យ។ បន្ថែមពីនេះ **ន.ធ.ក.** ក៏បានសម្របសម្រួលរៀបចំសិក្ខាសាលាស្តីពី អត្ថប្រយោជន៍ និងការប្រើប្រាស់ប្រព័ន្ធ Risk Analysis Toolkit ដោយសម្របសម្រួលអញ្ជើញក្រសួង ស្ថាប័នពាក់ព័ន្ធចូលរួមសិក្ខាសាលានេះផងដែរ។

❖ **ការរៀបចំវេទិកាថ្នាក់តំបន់របស់ ន.ធ.ក.**

ដើម្បីគាំទ្រការរៀបចំវេទិកាបង្ហាញជាសាធារណៈ (Showcase Event) សម្រាប់ការធ្វើជាប្រធានកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលធនាគារកណ្តាលអាស៊ាន នៅឆ្នាំ២០២២ **ន.ធ.ក.** បានរៀបចំឯកសារទស្សនទានស្តីពីវេទិកាថ្នាក់តំបន់នេះ ក្រោមប្រធានបទ "នវានុវត្តបច្ចេកវិទ្យា និងផលប៉ះពាល់លើការធានារ៉ាប់រង៖ កិច្ចប្រឈម, កាលានុវត្តភាព និងភាពឆ្ពោះទៅមុខ (Technological Innovations and Impact on Insurance: Challenges, Opportunities and Way Forward)" និងគ្រោងរៀបចំនៅក្នុងអំឡុងខែកញ្ញា ឆ្នាំ២០២២។

**<u>រូបភាពទី៣៧</u>**÷ កិច្ចប្រជុំពិភាក្សាលើការរៀបចំវេទិកាបង្ហាញជាសាធារណៈ (Showcase Event)



### ❖ កិច្ចប្រជុំគណៈកម្មាធិការស្តីពីសេរីភាវូបនីយកម្មសេវាហិរញ្ញវត្ថុអាស៊ាន (WC-FSL)

**គ.ធ.ភ.** បានចាត់តំណាងចូលរួមកិច្ចប្រជុំគណៈកម្មាធិការ ស្តីពីសេរីភាវូបនីយកម្មសេវាហិរញ្ញវត្ថុអាស៊ាន លើកទី៧៣ (73rd WC-FSL) នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២១ តាមរយៈប្រព័ន្ធវីដេអូអនឡាញ ក្នុងគោលបំណងធ្វើបច្ចុប្បន្នភាពវឌ្ឍនភាពនៃសកម្មភាពការងារ ក៏ដូចជាបន្តកិច្ចពិភាក្សាលើចំណុចសំខាន់ៗមួយចំនួន រួមមាន÷ ១). ការពិភាក្សាលើជម្រើសនៃការរៀបចំការចុះហត្ថលេខាលើពិធីសារទី៩, ២). ការពិភាក្សាលើរបៀបវារៈនិងបញ្ហាពាក់ព័ន្ធនឹងកិច្ចប្រជុំត្រៀមលើកទី៤ របស់អាស៊ាន (the 4th ASEAN SC-FS Caucus) និងកិច្ចប្រជុំ AANZFTA SC-FS លើកទី៤ និង ៣). គំនិតផ្តួចផ្តើមសម្រាប់ការរៀបចំកម្មវិធីសិក្ខាសាលាកសាងសមត្ថភាពសម្រាប់ប្រទេសជាសមាជិកអាស៊ាន។

# ផ្នែកទី៥: ក្របខណ្ឌបញ្ញត្តិកម្ម

នៅក្នុងឆ្នាំ២០២១ អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលមានសមត្ថកិច្ចជាបញ្ញត្តិកររបស់វិស័យធានារ៉ាប់រង បានរៀបចំក្របខណ្ឌច្បាប់និងបទប្បញ្ញត្តិមួយចំនួន ដើម្បីគ្រប់គ្រងនិងត្រួតពិនិត្យអាជីវកម្មធានារ៉ាប់រងនៅកម្ពុជា មានដូចខាងក្រោម៖

❖ **បទប្បញ្ញត្តិពាក់ព័ន្ធនឹងក្របខណ្ឌស្ថាប័ន** រួមមាន៖

- អនុក្រឹត្យលេខ ២៧៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការធានារ៉ាប់រង ជំនួសឱ្យអនុក្រឹត្យស្តីពីការធានារ៉ាប់រងឆ្នាំ២០០១
- ប្រកាសលេខ ០០៥ អ.ស.ហ.ប្រក ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទរបស់និយ័តករធានារ៉ាប់រងកម្ពុជា
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជា ២០២១-២០៣០ អនុម័តនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១

__រូបភាពទី ៣៩__÷ កិច្ចប្រជុំ “ក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ” លើកទី៥ អាណត្តិទី១ តាមរយៈប្រព័ន្ធវីដេអូអនឡាញ នាថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២១ ដើម្បីពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការធានារ៉ាប់រង



**<u>រូបភាពទី ៤០</u>**÷ កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្ដីព្រាងអនុក្រឹត្យស្ដីពីការធានារ៉ាប់រងដែលបានរៀបចំឡើងដោយ នាយកដ្ឋានធានារ៉ាប់រង និងសោធន នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៨



**<u>រូបភាពទី៤១</u>** ÷ កិច្ចប្រជុំអន្តរក្រសួងកម្រិតបច្ចេកទេសលើសេចក្ដីព្រាងអនុក្រឹត្យស្ដីពី ការធានារ៉ាប់រង នៅទីស្ដីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០



**<u>រូបភាពទី៤២</u> ÷** កិច្ចប្រជុំពិគ្រោះយោបល់ជាមួយអង្គការជាដៃគូអភិវឌ្ឍន៍ និងសមាគមធានារ៉ាប់រងកម្ពុជាលើសេចក្តីព្រាង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងរយៈពេល ១០ ឆ្នាំ (២០២១-២០៣០) តាមរយៈប្រព័ន្ធវីដេអូអនឡាញ កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១




**<u>រូបភាពទី៤៣</u> ÷** កិច្ចប្រជុំពិគ្រោះយោបល់ជាមួយបណ្តាក្រសួងស្ថាប័នពាក់ព័ន្ធ សមាគមធានារ៉ាប់រងកម្ពុជា គ្រឹះស្ថានធានារ៉ាប់រង និង ក្រុមហ៊ុនគណនេយ្យ និងសវនកម្ម លើសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រង រយៈពេល ១០ ឆ្នាំ (២០២១-២០៣០) តាមរយៈប្រព័ន្ធវីដេអូអនឡាញ កាលពីថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១



# ផ្នែកទី៦: ការងារសន្តមរបស់ ន.ធ.ក.

ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២១ តាមរយៈការអំពាវនាវរបស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ឯកឧត្តម **ម៉ៅ ចំនាន់ឌីរ៉ូ** អគ្គនាយក នៃនិយ័តករធានារ៉ាប់រងកម្ពុជា អមដោយថ្នាក់ដឹកនាំនិងមន្ត្រីរាជការរបស់និយ័តករធានារ៉ាប់រងកម្ពុជា បាននាំយកស្បៀងអាហារដែលទទួលបាន តាមរយៈការសហការឧបត្ថម្ភគាំទ្រ ពីបណ្តាគ្រឹះស្ថានធានារ៉ាប់រងនៅកម្ពុជា ដើម្បីចែកជូនប្រជាពលរដ្ឋក្រីក្រ និងទទួលរងផលប៉ះពាល់ដោយជំងឺកូវីដ-១៩ នៅក្នុងភូមិបារាជ ឃុំស្វាយជ្រុំ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល សរុបចំនួន ៩៤ គ្រួសារ ដោយបានចែកជូននូវ អង្ករចំនួន ១០គីឡូ មី ១កេស និងត្រីខ ២យួរក្នុងមួយគ្រួសារ និងបានប្រគេនឧបត្ថម្ភព្រះសង្ឃដែលគង់នៅវត្តបារាជ ជាអង្ករចំនួន ១៦០គីឡូ មី ១១កេស ត្រីខ ១២យួរ ទឹកត្រី ៥យួរ និងទឹកស៊ីអ៊ីវ ៥យួរផងដែរ។

<u>**រូបភាពទី៤៥÷**</u> ការសហការឧបត្ថម្ភគាំទ្រជាស្បៀងអាហារ ពីបណ្តាគ្រឹះស្ថានធានារ៉ាប់រងនៅកម្ពុជា ដើម្បីចែកជូនប្រជាពលរដ្ឋក្រីក្រ កាលពីថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២១



ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២១ តាមរយៈការអំពាវនាវរបស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ឯកឧត្តម **ច៊ូ ចំនួនតិរ្យ** អគ្គនាយកនៃនិយ័តករធានារ៉ាប់រងកម្ពុជា អមដោយថ្នាក់ដឹកនាំនិងមន្ត្រីនៃនិយ័តករធានារ៉ាប់រងកម្ពុជា ព្រមទាំងមានការចូលរួមពីតំណាងគ្រឹះស្ថានធានារ៉ាប់រងនានា បានពាំនាំយកអំណោយសប្បុរសធម៌ជាស្បៀងដែលមានដូចជា៖ អង្ករ មី ត្រីខ ទឹកត្រី ទឹកស៊ីអ៊ីវ និងសៀងជាដើម ដែលទទួលបានពីការសហការឧបត្ថម្ភគាំទ្ររបស់បណ្តាគ្រឹះស្ថានធានារ៉ាប់រង ដើម្បីប្រគល់ជូនរដ្ឋបាលស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល តាមរយៈ លោក **ម៉ិន ផេង** អភិបាលនៃគណៈអភិបាលស្រុកខ្សាច់កណ្តាល ដើម្បីប្រើប្រាស់ក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ នៅស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។

<u>***រូបភាពទី៤៦÷***</u> ការសហការឧបត្ថម្ភគាំទ្រជាស្បៀងអាហារ ពីបណ្តាគ្រឹះស្ថានធានារ៉ាប់រងនៅកម្ពុជា ដើម្បីចែកជូនប្រជាពលរដ្ឋក្រីក្រ តាមរយៈរដ្ឋបាលស្រុកខ្សាច់កណ្តាល កាលពីថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២១



ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២១ និយ័តករធានារ៉ាប់រងកម្ពុជា និង ក្រុមហ៊ុន **ព្រូដិនសល (ខេមបូឌា) ឡាយហ្វ៍ អឹស្សួរិនស៍ ម.ក** បានរៀបចំកម្មវិធី ចុះចែកសំភារៈបរិក្ខារអនាម័យជូន វិទ្យាល័យ អនុវិទ្យាល័យ បឋមសិក្សា សាលាមត្តេយ្យ និងមណ្ឌលសុខភាព ក្នុងឃុំរាមអណ្ដើក ខេត្តតាកែវ។

កម្មវិធីនេះដឹកនាំដោយ ឯកឧត្តម **ប៊ូ ច័ន្ទតិរ៉ូ** អគ្គនាយកនៃនិយ័តករធានារ៉ាប់រងកម្ពុជា អមដោយថ្នាក់ដឹកនាំ និងមន្ត្រីនៃនិយ័តករធានារ៉ាប់រងកម្ពុជា និងមានការចូលរួមពីតំណាងក្រុមហ៊ុន តំណាងអាជ្ញធរឃុំ នាយក នាយករងសាលាក្នុងឃុំ ប្រធានមណ្ឌលសុខភាពឃុំ លោកគ្រូពេទ្យ អ្នកគ្រូពេទ្យ លោកគ្រូ អ្នកគ្រូ និង សិស្សានុសិស្ស ឃុំរាមអណ្ដើកផងដែរ។

**រូបភាពទី៤៧÷** ការសហការឧបត្ថម្ភជាសំភារៈបរិក្ខារអនាម័យ របស់ក្រុមហ៊ុនព្រូដិនសល (ខេមបូឌា) ឡាយហ្វ៍ អឹស្សួរិនស៍ ម.ក. ដើម្បីចែកជូនគ្រឹះស្ថានអប់រំនានាក្នុងឃុំរាមអណ្ដើក កាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២១



# ផ្នែកទី៧: សន្និដ្ឋាន

**នៅក្នុងឆ្នាំ២០២១នេះ** កម្ពុជាក៏ដូចជាប្រទេសដទៃទៀតជុំវិញពិភពលោក នៅបន្តជួបប្រទះនូវបញ្ហាអូសបន្លាយនៃវិបត្តិជំងឺកូវីដ-១៩ ដែលបានរាំងស្ទះដល់ដំណើរការនៃសកម្មភាពសេដ្ឋកិច្ចទូទៅជាអន្លើៗ។ ទោះជាយ៉ាងណាក៏ដោយ ជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល តាមរយៈការដាក់ចេញនូវវិធានការជាច្រើនជំហានកន្លងមក កម្ពុជាបាននិងកំពុងសម្របខ្លួនបន្តិចម្តងៗទៅនឹងការរៀនរស់តាមគន្លងប្រក្រតីថ្មី (New Normal) ដែលប្រការនេះជំរុញឱ្យកម្ពុជាឈានទៅចាប់យកនូវកាលានុវត្តភាពថ្មីៗក្នុងតំបន់ និងសកលលោក។

ក្នុងន័យនេះ “**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជា ២០២១-២០៣០**” ដែលទទួលបានការឯកភាពដាក់ឱ្យប្រើប្រាស់ដោយក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១ គួបផ្សំនឹងបរិបទធូរស្រាលនៃវិបត្តិកូវីដ១៩នេះ នឹងក្លាយជាចំណុចរបត់ថ្មីមួយ នៃការចាប់ផ្តើមផ្តល់នូវសន្ទុះបន្ថែមក្នុងការអភិវឌ្ឍវិស័យធានារ៉ាប់រងនៅកម្ពុជា។ បន្ថែមពីនេះ វិបត្តិជំងឺកូវីដ-១៩ បច្ចុប្បន្នក៏បានឆ្លុះបង្ហាញឱ្យឃើញផងដែរ ពីសារៈសំខាន់កាន់តែខ្លាំងឡើងនៃវិស័យធានារ៉ាប់រង ជាពិសេសការធានារ៉ាប់រងអាយុជីវិត តាមរយៈការផ្តល់នូវយន្តការបន្ថែមការគាំទ្រទៅដល់វិស័យសន្តិសុខសង្គម ដោយបានកាត់បន្ថយឬសម្រាលនូវបន្ទុកហិរញ្ញវត្ថុរបស់បុគ្គល គ្រួសារ និងសង្គម នៅពេលមានការបាត់បង់អាយុជីវិតរបស់ជនបង្គោលគ្រួសារដែលមានការធានារ៉ាប់រងលើមរណភាពដោយសារជម្ងឺកូវីដ-១៩។

បច្ចុប្បន្ន នៅកម្ពុជាមានគ្រឹះស្ថានធានារ៉ាប់រងចំនួន ៨០ មានបុគ្គលជាភ្នាក់ងារធានារ៉ាប់រងចំនួនជាង ៥,០០០នាក់ មានទ្រព្យសកម្មសរុបចំនួនប្រមាណ ៨៤៥លានដុល្លារអាមេរិក និងមានមូលនិធិភាគទុនិកចំនួនប្រមាណ ៣៧៨លានដុល្លារអាមេរិក ជាមួយនឹងបុព្វលាភធានារ៉ាប់រងដុលប្រមាណ ២៩៨លានដុល្លារអាមេរិកក្នុងឆ្នាំ២០២១។ ទំហំទីផ្សារធានារ៉ាប់រងនៅបន្តកើនឡើងក្នុងឆ្នាំ២០២១ ដែលក្នុងនោះវិស័យធានារ៉ាប់រងបានរួមវិភាគទានក្នុងសេដ្ឋកិច្ច ជាអត្រាប្រមាណ ១,១១% ជាមួយដង់ស៊ីតេធានារ៉ាប់រងប្រមាណ ១៨,៧៥ ដុល្លារអាមេរិកក្នុងមនុស្សម្នាក់ៗ។ ជាមួយនឹងភាពធន់មាំនៃវិស័យធានារ៉ាប់រង ជាពិសេសនៅក្នុងអំឡុងពេលបិទខ្ទប់ដោយសារជំងឺកូវីដ-១៩ និងការបង្ហាញពីការប្តេជ្ញាចិត្តនិងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជា **ន.ធ.ភ.** លើការចាប់យកប្រព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ ទីផ្សារធានារ៉ាប់រងកម្ពុជា នៅមានសក្តានុពលខ្ពស់លើភាពប្រកួតប្រជែង ឱកាសការងារ និងភាពទាក់ទាញវិនិយោគទាំងក្នុងស្រុកនិងពីបរទេស ធៀបជាមួយនឹងបណ្តាប្រទេសនានាក្នុងតំបន់អាស៊ីអាគ្នេយ៍។

**និយ័តករធានារ៉ាប់រងកម្ពុជា**

© 2022, រក្សាសិទ្ធិដោយនិយ័តករធានារ៉ាប់រងកម្ពុជា

អគារលេខ ១៦៨F (ជាន់ទី៦) ផ្លូវលេខ ៥៩៨ សង្កាត់ច្រាំងចំរេះ១

ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កម្ពុជា

www.irc.gov.kh

សម្របសម្រួលដោយ នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល
និងសហប្រតិបត្តិការ